សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit et des Sciences Economiques

Royal University of law and Economics

## សារណាបញ្ចប់ការសិក្សា

# លំហូរនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក គន់ ដារ៉ាក់**

**លោក ឈួន មុន្នីរិទ្ធិ**

ណែនាំដោយ

លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០២០

ជំនាន់ទី ២៤

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរឈ្មោះ **គន់ ដារ៉ាក់** និង **ឈួន មុន្នីរិទ្ធិ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី ២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។**

យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្តាយ យើងទាំងពីរដែលលោកបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់មើលថែរក្សាថ្នាក់ថ្នមយើងខ្ញុំតាំងពីពេលចាប់កំណើតមករហូតមកដល់សព្វថ្ងៃនេះដោយក្តីសណ្តោសប្រណី និងព្រហ្មវិហារធម៌ ជាពិសេសគឺជាអ្នកដែលបានដែលបានផ្តល់នូវការអប់រំទូន្មានមុនដំបូងគេបង្អស់ ដល់យើងខ្ញុំទាំងពីរអ្នក លើសពីនេះទៅទៀត លោកអ្នកគុណតែងតែទំនុកបម្រុងជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងសម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់មត្តេយ្យរហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សាបរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ដោយពុំដែលត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយដែលទាំងនេះគឺជាកម្លាំងជំរុញដ៏ធំអស្ចារ្យបំផុតមួយនៅពីក្រោយភាពជោគជ័យរបស់យើងខ្ញុំទាំងពីររូបក្នុងពេលបច្ចុប្បន្ននេះ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរស និងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ អប់រំ ជ្រុមជ្រែង និងចែករំលែកចំណេះដឹងជូននិស្សិតកន្លងមក។

សូមថ្លែងអំណរគុណដល់ **លោក តា សុទ្ធា** ដែលលោកបានព្រមទទួលយកនូវការដឹកនាំក្នុងការសរសេរសាណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបណ្តុះបណ្តាល ពន្យល់ណែនាំផ្តល់ជាគតិគំនិតដើម្បីបំភ្លឺយើងខ្ញុំក្នុងរយៈពេលកន្លងមកនេះ រហូតយើងខ្ញុំបានចងក្រងនូវ សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរជាពិសេសសូមប្រសិទ្ធពរជ័យ សិរីសួស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ជំនាន់ទី២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**ក្នុងឆ្នាំសិក្សា២០២០-២០២៤ អស់រយៈពេល៤ឆ្នាំកន្លងមក ដោយមានការជ្រោមជ្រែងពីលោកគ្រូអ្នកគ្រូ សាស្រ្តាចារ្យព្រមទាំងការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងការស្តាប់ដំបូន្មានល្អៗពីសំណាក់សិស្សច្បងលោកគ្រូអ្នកគ្រូ សាស្រ្តាចារ្យ នៅក្នុងសាកលវិទ្យាល័យបានធ្វើឲ្យយើងខ្ញុំទាំងពីររូប ទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **លំហូរនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ** ។

យើងខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដែលបានសរសេរ និងរៀបរៀង សារណារបញ្ចប់ការសិក្សាក្រោមប្រធានបទ **លំហូរនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ** ក្រោមការណែនាំពីលោកគ្រូ **តា សុវណ្ណា** ដែលលោកសាស្រ្តាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវចំនេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិគតិដល់ក្រុមយើងខ្ញុំ ។ សារណាមួយនេះផងដែលគឺជាការស្រាវជ្រាវប្រមូលផ្តុំឯកសារ វិធានច្បាប់ និងនីតិវិធីព្រហ្មទណ្ឌតាមលំដាប់ ពីមន្រ្តីនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលចៅក្រមជម្រះក្តី។

ជាការពិតណាស់នីតិវិធីព្រហ្មទណ្ឌពិតជាមានសារៈសំខាន់ចំពោះអ្នកអនុវត្តច្បាប់ព្រោះវាជាផ្លូវ ជាក្បួនច្បាប់អោយអ្នកអនុវត្តដើរតាម ធ្វើការអនុវត្តត្រឹមត្រូវមានអានុភាព តម្លាភាពនឹងយុត្តិធម៌ ចំពោះជនល្មើស និងជនរងគ្រោះស្មើៗគ្នា។ ការធ្វើសារណាមួយនេះ គឺក្នុងគោលបំណងជួយផ្សព្វផ្សាយពីលំដាប់លំដោយ លំហូរនីតិវិធីក្នុងការងារវិស័យច្បាប់នៅកម្ពុជា និងអាចផ្តល់ជាជំនួយស្មារតីដល់ប្អូនៗ និស្សិតជំនាន់ក្រោយៗទៀត ដើម្បីបង្កើននូវចំណេះដឹងក្នុងការយល់ដឹងអំពីច្បាប់អោយកាន់តែទូលំទូលាយជាងនេះទៅទៀត ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា ការខិតខំស្រាវជ្រាវធ្វើសារណាមួយនេះនឹងជួយផ្តល់នូវផលប្រយោជន៍ជាច្រើនដល់ប្អូនៗ និស្សិតជំនាន់ក្រោយៗទៀត ក្នុងការធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងនីតិវិធីច្បាប់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ដំណាក់កាលស៊ើបអង្កេត

**ផ្នែកទី១ ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌** ........ ៦

**១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌** ........ ៧

១.១.១. មន្ត្រីនគរបាលយុត្តិធម៌ ........ ៧

១.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌ ........ ៨

១.១.៣. ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា ........ ៩

**១.២. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ........ ១០

១.២.១. លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ........ ១០

១.២.២. ដំណើរការស៊ើបអង្កេត ........ ១០

១.២.៣. វិធានការនៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១២

១.២.៤. វិធានក្នុងការឃាត់ខ្លួន ........ ១៤

**១.៣. ការស៊ើបអង្កេតបឋម** ........ ១៧

១.៣.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទល្មើសមិនជាក់ស្តែង ........ ១៧

១.៣.២. វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន ........ ១៩

១.៣.៣. វិធានពិសេសក្នុងការស៊ើបអង្កេតករណីបឋម ........ ១៩

**ផ្នែកទី២ ដំណាក់កាលអយ្យការ** ........ ១៩

**២.១. អង្គការអយ្យការ** ........ ២០

២.១.១. អំណាចរបស់អង្គការអយ្យការ ........ ២០

២.១.២. ឋានុក្រមនៃចៅក្រមអយ្យការ ....................................................................... ២០

២.១.៣. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់....................................................... ២២

២.១.៤. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ................................... ២២

**២.២. ការធ្វើបណ្តឹងអាជ្ញា**........................................................................................ ២៤

២.២.១. ជម្រើសការចោទប្រកាន់ ....................................................................................... ២៤

២.២.២. ការបើការស៊ើបសួរ ............................................................................................. ២៤

២.២.៣. នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនផ្ទាល់ ................................................................. ២៧

២.២.៥. ការតម្កល់រឿងទុកឥតចាត់ការ ............................................................................. ២៨

## ជំពូកទី២

## ជំណាក់កាលស៊ើបសួរ

**ផ្នែកទី១ យុត្តាធិការស៊ើបសួរ** ....................................................................................... ៣៣

**១.១ចៅក្រមស៊ើបសួរ**............................................................................................ ៣៣

១.១.១. សមត្ថកិច្ចដែនដី................................................................................................ ៣៣

១.១.២.សមត្ថកិច្ចតាមសាច់រឿង .................................................................................. ៣៤

**១.២. សភាស៊ើបសួរ** .................................................................................................. ៣៥

**១.៣.ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ**......................................... ៣៦

១.៣.១.ប្រភេទនៃបណ្តឹង................................................................................................ ៣៦

១.៣.២.វិសាលភាពនៃបណ្តឹង ......................................................................................... ៣៦

**១.៤.ការបញ្ចប់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ** ............................................................ ៣៧

១.៤.១.ការជូនដំណឹងអំពីកិច្ចបញ្ចប់ការស៊ើបសួរ............................................................ ៣៧

១.៤.២.ការបញ្ចប់ការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី ................................................ ៣៧

១.៤.៣.ដីកាដំណោះស្រាយ ........................................................................................... ៣៨

១.៤.៤.អានុភាពនៃដីកាដំណោះស្រាយ ............ ៣៨

**ផ្នែកទី២ សិទ្ធិអំណាចចៅក្រមស៊ើបសួរ** ............ ៣៩

**២.១.អំណាចបង្ខំរបស់ចៅក្រម** ............ ៣៩

២.១.១. ការចេញដីកា ............ ៣៩

២.១.២. ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ............ ៤២

២.១.៣.ការរក្សារជនត្រូវចោទឲ្យស្ថិតក្រោមការចាត់ចែងរបស់តុលាការ ............ ៤៤

**២.២.អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............ ៤១

២.២.១. អំណាចរបស់ចៅក្រមស៊ើបសួរ ............ ៥១

២.២.២.មោឃភាពនៃការស៊ើបសួរ ............ ៥៧

## ជំពូកទី៣

## ដំណាក់កាលជំនុំជម្រះ

**ផ្នែកទី១ យុត្តាធិការជម្រះ** ............ ៦០

**១.១.សមត្ថកិច្ច និងការប្តឹងទៅតុលាការ** ............ ៦០

**១.២.ការរៀបចំសវនាការ** ............ ៦១

១.២.១.ការចាត់តាំងចៅក្រមជំនុំជម្រះ និងកំណត់ពេលសវនាការ ............ ៦១

១.២.២.ការកោះហៅចូលសវនាការ ............ ៦១

**១.៣. ការពិភាក្សាដេញដោល** ............ ៦៤

១.៣.១.សន្តិសុខ និងសណ្តាប់ធ្នាប់ ............ ៦៤

១.៣.២.ដំណើរនៃកិច្ចពិភាក្សាដេញដោល ............ ៦៥

១.៣.៣.ការដាក់ភស្តុតាងជូនតុលាការពិនិត្យ ............ ៦៦

**១.៤. ការប្រកាសសាលក្រម** ............ ៦៧

១.៤.១. ការប្រកាសពិរុទ្ធភាព ............ ៦៨

១.៤.២. ការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី......................................................................៦៩

១.៤.៣ ការសម្រេចអំពីវត្ថុចាប់យក ..................................................................................................៦៩

**ផ្នែកទី២ អំពីសាលក្រម**..........................................................................................................................៦៩

**២.១.ប្រភេទនៃសាលក្រម** ..........................................................................................................................៧០

**២.២.និទ្ទេសដែលត្រូវចុះជាភាគព្វកិច្ចក្នុងសាលក្រម**.................................................................................... ៧២

**២.៣.ការជូនដំណឹងអំពីសាលក្រម**...............................................................................................................៧៣

**ផ្នែទី៣ ប្តឹងតវ៉ា** ........................................................................................................................................៧៣

**៣.១ បណ្តឹងតវ៉ាសាមញ្ញ** ..............................................................................................................................៧៣

៣.១.១. បណ្តឹងទាស់...................................................................................................................៧៣

៣.១.២. បណ្តឹងឧទ្ធរណ៍ ...............................................................................................................៧៤

**៣.២ បណ្តឹងតវ៉ាវិសាមញ្ញ** ..........................................................................................................................៧៦

៣.២.១.បណ្តឹងសាទុក្ខ ..................................................................................................................៧៦

៣.២.២.បណ្តឹងសើរើ.................................................................................................................... ៧៧

**សេចក្តីសន្និដ្ឋាន** ....................................................................................................................................... ៧៩

**អនុសាសន៍** ...............................................................................................................................................៨១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅប្រទេសយើងសព្វថ្ងៃប្រជាជនគ្រប់រូបទាំងអស់គួរតែយល់ដឹងពីច្បាប់ឲ្យកាន់តែច្បាស់ ដើម្បីធានានៅប្រសិទ្ធភាពនៅក្នុងការអនុវត្ត។ ព្រោះថាគ្រប់ប្រជាជននៅក្នុងសម័យទំនើបទាំងអស់ សុទ្ធតែត្រូវប្រឈមមុខនឹងការយល់ដឹង ការផ្សព្វផ្សាយច្បាប់ ដើម្បីឲ្យការគ្រប់គ្រង និងធានាឲ្យមានសន្តិភាពក្នុងសង្គម។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្កើតឲ្យមាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ ២០០៧ ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ។ នីតិវិធីព្រហ្មទណ្ឌសំដៅលើ ដំណើរការនៃការប្រព្រឹត្តទៅនៅក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ហើយវានឹងបង្ហាញដល់អ្នកសិក្សាឲ្យយល់ដឹងពីការអនុវត្តនីតិវិធី និងវិធានទាំងឡាយដែលបានបកស្រាយដោយភាគីដែលបានចូលរួមនៅក្នុងដំណើរការនៃកិច្ចរបស់តុលាការ។ នីតិវិធី និងវិធានទាំងនោះមានប្រភពពីច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិដែលរួមមានសន្ធិសញ្ញា អនុសញ្ញា និងពិធីសារផ្សេងៗទៀត។ ក្រៅពីនោះមានច្បាប់ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ដែល សភា និងស្ថាប័ននានារបស់កម្ពុជាបានអនុម័ត។

នៅក្នុងនីតិវិធីព្រហ្មទណ្ឌមានកំណត់យ៉ាងច្បាស់លាស់អំពីទម្រង់នៃបណ្តឹងនិងបែបបទនៃការធ្វើបណ្តឹងដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធយុត្តាធិការនៅប្រទេសកម្ពុជា ។ លំហូរនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ គឺជាកិច្ចស្រាវជ្រាវដែលបានបង្ហាញអំពីនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ ដែលរៀបរាប់ចាប់ពី ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមុខងារនៃអង្គការអយ្យការ ចៅក្រមស៊ើបសួរ រហូតដល់ចៅក្រមជំនុំជម្រះ ចេញសេចក្តីសម្រេច ដែលមានច្រើនដំណាក់កាលទម្រាំនឹងដល់នូវកិច្ចបញ្ចប់ចុងក្រោយ និងដែលរៀបរាប់ អំពីលំហូរនៃនីតិវិធីជំនុំជម្រះនៅសាលាដំបូង(តុលាការជាន់ទាប) ព្រមទាំងការប្តឹងតវ៉ាទៅកាន់សាលាឧទ្ធរណ៍ដែលជាតុលាការជាន់ខ្ពស់។ដំណាក់កាលទាំងអស់នេះមាន លក្ខណៈស្មុគស្មាញ ដោយត្រូវឆ្លងកាត់នូវច្រើននីតិវិធី ហេតុនេះហើយទើបប្រធានបទនេះតម្រូវអោយមានការវែកញែកនៃនីតិវិធីនីមួយៗឲ្យបានច្បាស់លាស់ និងដាច់ដោយឡែកពីគ្នាដើម្បីមានភាពងាយស្រួលនៅក្នុងការសិក្សាស្វែងយល់នូវនីតិវិធីនីមួយៗខាងលើនេះ។

ដូចដែលបញ្ជាក់ខាងលើនេះហើយទើបយើងខ្ញុំធ្វើការបកស្រាយឲ្យបានច្បាស់លាស់បន្ថែមចំពោះចំណុចនីមួយៗ អំពីកិច្ចការសារណានេះទៅតាមកម្រិតថ្នាក់បរិញ្ញាបត្រសម្រាប់និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បី

ជាការចែករំលែកជាចំណេះដឹងជូនដល់មិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយណាដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវស្វែងយល់ពីលំហូរនីតិវិធីនៃដោះស្រាយរឿងក្ដីព្រហ្មទណ្ឌនេះ ដើម្បីជាចំណេះដឹង និងជាពិសេសសម្រាប់អ្នកដែលចង់ក្លាយខ្លួនជាអ្នកអនុវត្តច្បាប់ផ្នែកយុត្តាធិការជាដើម។

## ២. ចំណោទបញ្ហា

ដើម្បីជាការយល់ដឹងឲ្យបានកាន់តែច្បាស់លាស់ស៊ីជម្រៅនូវលំហូរនីតិវិធីក្នុងការដោះស្រាយរឿងក្ដីនៃបណ្ដឹងព្រហ្មទណ្ឌ យើងត្រូវដឹងនូវការចំណុចសំខាន់ៗមួយចំនួនដែលជាគោលការណ៍ពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីតួនាទី និងតួអង្គដែលសំខាន់ៗក្នុងដំណើរការនៃនីតិវិធីខាងលើដូចជា៖

- តើដំណើរការរឿងក្ដីព្រហ្មទណ្ឌជាអ្វី?
- តើដំណើរការរឿងក្ដីព្រហ្មទណ្ឌមានតួអង្គសំខាន់ណាខ្លះ?
- តើតួអង្គសំខាន់ក្នុងដំណើរការរឿងក្ដីនោះមានតួនាទីក្នុងការអនុវត្តនីតិវិធីដូចម្ដេចខ្លះ?
- តើគេអាចប្ដឹងតវ៉ានឹងសេចក្ដីសម្រេចបានដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានគោលបំណងក្នុងការចែករំលែកនូវពុទ្ធិចំណេះដឹងខ្លះៗក្នុងការដោះស្រាយរឿងក្ដីព្រហ្មទណ្ឌដែលជា នីតិវិធីរបស់តុលាការដែលមានសារៈប្រយោជន៍យ៉ាងសំខាន់ណាស់ក្នុងប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចការស្រាវជ្រាវមួយនេះ គឺជាស្នាដៃមួយដែលបានតាក់តែងឡើង ដើម្បីទុកជាជំនួយដល់និស្សិតមិត្តអ្នកសិក្សាស្រាវជ្រាវ ដែលចង់ស្វែងយល់ពីដំណើរការរឿងក្ដីព្រហ្មទណ្ឌដែលជានីតិវិធីនៃតុលាការរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

កិច្ចការសិក្សាស្រាវជ្រាវនៃសារណាបញ្ចប់ឆ្នាំសិក្សាមួយនេះ ផ្ដោតសំខាន់ទៅលើដំណើរការដោះស្រាយរឿងក្ដីព្រហ្មទណ្ឌរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជាទៅតាមដំណាក់កាល ចាប់ផ្ដើមតាំងពីដំណាក់កាលដំបូង ពោលគឺការដាក់ពាក្យបណ្ដឹងរហូតដល់មានការជំនុំជម្រះ ហើយបានចេញនូវសេចក្ដីសម្រេចរបស់តុលាការ។ កិច្ចការស្រាវជ្រាវនេះក៏នឹងបង្ហាញអំពីតួនាទី និងភារកិច្ចរបស់តួអង្គនីមួយៗ នៅក្នុងសាលាជម្រះក្ដីនៅពេលដែល

ខ្លួនបានទទួលនូវពាក្យបណ្ដឹងហើយនឹងមានចំណាត់ការស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងវិជ្ជាជីវៈរបស់ខ្លួនទៅតាមមុខងារផ្សេងៗគ្នា។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានឯកសារ និងព័ត៌មានទាំងអស់ដើម្បីយកមកចងក្រងឯកសារ គឺបានឆ្លងកាត់ការស្រាវជ្រាវដោយប្រើប្រាស់ឯកសារជាចម្បងមួយចំនួនដូចជាច្បាប់រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត និងតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរពិគ្រោះសុំយោបល់ពីសំណាក់លោកសាស្ត្រាចារ្យណែនាំនិងសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់នូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់ប្រធានបទយើងខ្ញុំ។ បន្ទាប់ពីទទួលបានឯកសារ និងព័ត៌មានទាំងអស់នេះហើយគឺត្រូវបានយកមកពិនិត្យមុននឹងជ្រើសរើសមកចងក្រងជាខ្លឹមសារសម្រាប់អត្ថបទមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ ត្រូវបានបែងចែកដូចខាងក្រោម៖

- **ជំពូកទី១ ដំណាក់កាលស៊ើបអង្កេត**
- **ជំពូកទី២ ដំណាក់កាលនៃការស៊ើបសួរ**
- **ជំពូកទី៣ ដំណាក់កាលជំនុំជម្រះ**

# ជំពូកទី១

# ដំណាក់កាលស៊ើបអង្កេត

# ជំពូកទី១
# ជំណាក់កាលស៊ើបអង្កេត

## ផ្នែកទី១ ជំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការ[1] នគរបាលយុត្តិធម៌ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

ព្រះរាជអាជ្ញាដឹកនាំនឹងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងដែនសមត្ថភាពរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចចៅក្រមស៊ើបសួរ[2] ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ បានដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌។[3]

### ១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

ដោយអនុលោមតាមមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ពីសមាសភាពរបស់នគរបាលយុត្តិធម៌ ដូចខាងក្រោម៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឲ្យធ្វើការត្រួតពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតកាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជា នគរបាលយុត្តិធម៌ ។

ក្រៅពីនេះ នគរបាលយុត្តិធម៌ ក៏ស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរ ដោយអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌បាន បន្ទាប់ពីមានការរាយការណ៍ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ ដោយអង្គព្រះរាជ

[1] មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[2] មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[3] មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អាជ្ញា ប្រកាស់ជូនដំណឹងដល់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ឬរដ្ឋមន្រ្តីក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ ក្រៅពីនេះ អង្គព្រះរាជអាជ្ញា ក៏អាចចេញវិធានការវិន័យដោយផ្ទាល់ទៅលើមន្រ្តីនគរបាលយុត្តិធម៌ដែរ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ក្រោយការកោះហៅមន្រ្តីនគរបាលយុត្តិធម៌នោះមកផ្តល់សេចក្តីអង្កេតរួចមក។

### ១.១.១. មន្រ្តីនគរបាលយុត្តិធម៌

សមាសភាពរបស់មន្រ្តីនគរបាលយុត្តិធម៌មានកំណត់នៅ មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមអត្ថន័យនៃមាត្រានេះ គុណសម្បត្តិជាមន្រ្តីនគរបាលយុត្តិធម៌អាចទទួលបានតាមរបៀប ២ (ពីរ) យ៉ាងគឺ ៖

- តាមការប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។
- តាមមុខងារដែល និង ឋានន្តរស័ក្តិរបស់មន្រ្តីនគរបាលយុត្តិធម៌ ។

តាមមាត្រា ៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្រ្តីនគរបាលយុត្តិធម៌ម្នាក់ៗត្រូវ ស្បថ នៅមុខសាលាឧទ្ធរណ៍ ។

### ១.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ គឺជានាយនគរបាល ស្នងការ និងអធិការនៃនគរបាលជាតិដែលពុំមានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ នាយកងរាជអាវុធហត្ថដែលពុំមានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ និងទាហានដទៃទៀតរបស់កងរាជអាវុធហត្ថ។ ភ្នាក់ងារនីមួយៗត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងរាជធានី ខេត្ត តាមប្រកាសចាត់តាំងដោយក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ ហើយត្រូវធ្វើសម្បថថាខ្លួននឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើស។អត្ថបទច្បាប់បានបញ្ជាក់ថាភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើសលហុជាដើម ។ ភ្នាក់ងារមន្រ្តីនគរបាលយុត្តិធម៌ ជូនដល់មន្រ្តីនគរបាលយុត្តិធម៌ក្នុងការបំពេញតួនាទីរបស់ខ្លួន ។ កំណត់ហេតុ ឬរបាយការណ៍របស់ភ្នាក់ងារនគរបាលយុត្តិធម៌មានតម្លៃត្រឹមជាព័ត៌មានធម្មតាតែប៉ុណ្ណោះ ។

### ១.១.៣. ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា

ក្នុងចំណោមបេសកកម្មដែល ទទួលបានភ្នាក់ងារសាធារណៈ ជាច្រើនមានបេសកកម្មបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើល្មើសទៅលើច្បាប់ដែលគ្រប់គ្រងវិស័យរបស់ខ្លួន ដូចជាពិនិត្យកត់ត្រាការប្រព្រឹត្ត ទាំងនេះជាដើម។ ភ្នាក់ងារនេះក៏ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា នៅពេលដែលខ្លួនបំពេញតួនាទីជានគរបាលយុត្តិធម៌។ មន្រ្តីរាជការ និងភ្នាក់ងារសាធារណៈទាំងនេះត្រូវធ្វើសម្បថថានឹងបំពេញតួនាទីដោយស្មោះត្រង់ចំពោះមុខសាលាដំបូង ។

ចំពោះបែបបទ និងនីតិវិធីនៃការផ្តល់នូវនីតិសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវបានកំណត់ដោយប្រកាសរួមរបស់ក្រសួងពាក់ព័ន្ធ និងក្រសួងយុត្តិធម៌ ។ ដូចគ្នាទៅនឹងផងដែរ មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈក្នុងការបំពេញមុខងាររបស់ខ្លួន របាយការណ៍គឺមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាតែប៉ុណ្ណោះ[4] ។

➢ **កំហុសមន្ត្រីនគរបាលយុត្តិធម៌**

រាល់ការប្រព្រឹត្តកំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់ដំណឹងដល់រដ្ឋមន្ត្រី (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌) ឬភ្នាក់ងារនោះនៅក្រោមវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើស ត្រូវបានប្រព្រឹត្ត[5] ។

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ដែលមានកំហុសទណ្ឌកម្មខាងវិន័យ ដែលត្រូវប្រកាសដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោមនេះ៖

- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។
- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈ ពេល ០៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

មុខនឹងចេញសេចក្តីសម្រេចខាងវិន័យខាងលើនេះអង្គព្រះរាជអាជ្ញា ត្រូវកោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកសេចក្តីសង្ខេបរបស់មន្ត្រីនោះ ។ សាមីខ្លួនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់តាមជម្រើសរើសរបស់ខ្លួន ។

ចំពោះសេចក្តីសម្រេចនេះត្រូវមានសំអាងហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ។ ចំពោះសេចក្តីសម្រេចប្រកាសវិន័យខាងលើនេះអាចធ្វើបណ្តឹងតវ៉ាទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្រកាសបដិសេធន៍សេចក្តីសម្រេចរបស់អង្គព្រះរាជអាជ្ញា ឬបន្ថយរយៈនៃសេចក្តីសម្រេចនោះ ។

[4] មាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[5] មាត្រា ៦៤ មាត្រា ៧៩ និងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ១.២. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេតគឺជាភាពបន្ទាន់ដែលតម្រូវឲ្យមានការប្រមូលនូវភស្តុតាងនៃបទល្មើសដែលនៅមាននៅឡើយ ដែលវាទើបត្រូវបានប្រព្រឹត្តថ្មីៗ ។

ការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាដំណាក់កាលដែលពុំអាចឲ្យពេលវេលាណាមួយត្រូវបានបាត់បង់ឡើយ ។ ការយឺតយ៉ាវតែបន្តិចបន្តួចអាចជាមូលហេតុនៃការបាត់នូវតម្រុយនៃពិរុទ្ធភាព ឬ ពិរុទ្ធជន និង ស្លាកស្នាមនៃបទល្មើសបាន។ ហេតុនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់ឲ្យកម្លាំងសាធារណៈដែលត្រូវប្រឈមនឹងបទល្មើសដែលទើបតែកើតឡើងភ្លាមៗ នូវមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយដើម្បីឆ្លើយតបនឹងល្បឿននៃការបាត់បង់នូវតម្រុយភស្តុតាង និងការរត់គេចខ្លួនរបស់ជនប្រព្រឹត្តបទល្មើស ឬអ្នកចូលរួមប្រព្រឹត្តបទល្មើស ។

### ១.២.១. លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង

យោងតាមបទញ្ញត្តិមាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាៈ ក្នុងករណីមានបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

មានន័យថានៅចំពោះមុខស្ថានភាពជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពនូវលក្ខខណ្ឌ នៃការស៊ើបអង្កេតជាក់ស្តែង ក្នុងករណីដែលបទល្មើសប្រព្រឹត្តជាប្រភេទបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ។

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺជាបទល្មើសដែលកំពុងប្រព្រឹត្តបទល្មើសដែលទើបប្រព្រឹត្តិរួចភ្លាម ។ ក្នុងនោះដែលក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់និយមន័យបទល្មើដែលត្រូវចាត់ទុកថាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែលកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមកជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីងបុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណាបទល្មើសដែលត្រូវបានប្រព្រឹត្តនោះនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនេះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ហើយភ្នាក់ងារ

នគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ [6] ។ ក្នុងករណីដែលមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

### ១.២.២. ដំណើរការស៊ើបអង្កេត

ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ ក្នុងករណីដែលបទល្មើសត្រូវចាត់ទុក ឬប្រដូចបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ថេរវេលានៃកាស៊ើបអង្កេតនេះ មិនរាប់បញ្ចូលរយៈពេលចន្លោះរវាងការប្រព្រឹត្តបទល្មើស និងការប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញានោះទេ ។ ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ត្រូវគិតពី ថ្ងៃដែលមានការពិនិត្យកត់ត្រាបទល្មើស មិនមែនពីថ្ងៃដែលបទល្មើសប្រព្រឹត្តនោះទេ ។

**ឧទាហរណ៍:** មានករណីយលួចគាស់ផ្ទះមួយយកម៉ូតូបានកើតឡើងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០១ ដែលម្ចាស់ផ្ទះមិននៅ រហូតដល់ថ្ងៃបន្ទាប់គឺនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ វេលាម៉ោង ១៥ ទើបម្ចាស់ផ្ទះ

ត្រឡប់មកផ្ទះវិញ ទើបដឹងថាមានចោរលួចគាស់ផ្ទះយកម៉ូតូ ។ ម្ចាស់ផ្ទះបានដាក់ពាក្យបណ្តឹង ហើយសមត្ថកិច្ចបានចុះមកពិនិត្យកន្លែងកើតហេតុនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ នៅវេលា ម៉ោង ១៦ និង ០០ នាទី ។ ដូចនេះថិរវេលានៃការស៊ើបអង្កេតត្រូវបានគិតចាប់ពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ ។

ដើម្បីឲ្យការស៊ើបអង្កេតនេះអាចធ្វើឡើងក្នុងថិរវេលាកំណត់នេះ ក្រមនីតិវិធីព្រហ្មទណ្ឌចែងអំពីលក្ខខណ្ឌទាមទារបន្ថែម ។ ដូចនេះការស៊ើបអង្កេតត្រូវធ្វើឡើងបន្តបន្ទាប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បើពុំនោះទេនាំឲ្យមានមោឃភាពនៃនីតិវិធី ។

បទប្បញ្ញត្តិនៃមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាផ្នែកមួយនៃវិធាន និងទម្រង់ការដែលបានចែង និងនាំឲ្យមានមោឃភាពក្នុងករណីមិនគោរព[7] ។

នៅពេលដែលថេរវេលានេះត្រូវបានបញ្ចប់ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនទាន់បញ្ចប់ការស៊ើបអង្កេត មន្ត្រីនេះត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ដែលពិនិត្យពិចារណាវាយតំលៃអំពីភាពចាំបាច់ក្នុងការបន្តការស៊ើបអង្កេតក្នុងក្របខណ្ឌការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ឬតម្កល់រឿងទុកមិនចាត់ការ ឬបញ្ជូនរឿងទៅសាលា

[6] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[7] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ជំនុំជម្រះក្តីដោយផ្ទាល់ ។ បើការស៊ើបអង្កេតត្រូវបានបញ្ចប់ កំណត់ហេតុ និងភស្តុតាងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា បើពុំនោះទេ នាំឲ្យមានមោឃភាពនៃនីតិវិធី[8] ។ ក្នុងអំឡុងពេលស៊ើបអង្កេត គ្រប់កិច្ចទាំងអស់ត្រូវតក់ត្រានៅនឹងកន្លែងកើតហេតុ ដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលដឹកនាំការស៊ើបអង្កេតនេះ ។

ឧទាហរណ៍: កំណត់ហេតុឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុស្តីពីការចាប់យកវត្ថុតាំង កំណត់ហេតុស្តីពីការឆែកឆេរ កំណត់ហេតុស្តីពីការពិនិត្យកន្លែងកើតហេតុជាដើម ។

### ១.២.៣. វិធានការនៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

តាមបញ្ញត្តិមាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា៖ ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូប កុំឲ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថាមានប្រយោជន៍ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានបានទទួលការអនុញ្ញាតជាបឋមពី ព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនេះធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយល័ក្ខណ៍អក្សរក្តី ។ វិធានក្នុងការឆែកឆេរនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌មិនផ្តើមការឆែកឆេរនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ។ តែចំពោះករណីយដែលមានបទ ល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ឬក្នុងករណីដែលចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានដោយពុំចាំបាច់

[8] មាត្រា ១០៧ នៃនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អនុលោមតាមលក្ខខ័ណ្ឌខាងលើនេះទេ ។ ក្រៅពីនេះក្នុងករណីយដែលមានសម្រែកស្រែកឲ្យគេជួយពីក្នុងកន្លែង ក្នុងករណីដែលពេលម៉ោងដែលបើកចំហរដល់សាធារណជន ក្នុងករណីដែលកន្លែងនោះជាកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន មន្ត្រីនគរបាលអាចធ្វើការឆែកឆេរដោយពុំចាំបាច់គោរព ពេលខាងលើនេះឡើយ[9] ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបាននោះទេ ការឆែកឆេរនេះ អាចត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដោយធ្វើឡើងនៅ ចំពោះមុខប្រធានគ ណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬ មេធាវីសាមី ។

ក្រៅពីការហាមឃាត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏មិនអាចធ្វើការឆែកឆេរបានផងដែរ នៅក្នុង អគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសព័ត៌មានសោតទស្សន៍ គឺអាចធ្វើទៅបាននៅ ចំពោះមុខនៃព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែម្នាក់ប៉ុណ្ណោះ ហើយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរត្រូវធានា ដល់ការឆែកឆេរមិនត្រូវឲ្យប៉ះពាល់ដល់ការប្រកបមុខរបបដោយសេរីនៃរបបអ្នកសារព័ត៌មានមិនត្រូវធ្វើឲ្យមាន យឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះឡើយ[10] ។

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ធ្វើការបិទ ស្លាកបោះត្រាលើវត្ថុចាប់យក (វត្ថុតាង) នោះ ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញ អ្នកកាន់កាប់ទី កន្លែង ឬសាក្សីពីរនាក់មើលរួច ធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យក នោះ ដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើកោះហៅ ឬមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ ការស្តាប់ចម្លើយ (សួរយកចម្លើយ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រី នគរបាលយុត្តិធម៌ ។ ក្នុងករណីដែលជនត្រូវបានស្តាប់ចម្លើយជាជនបរទេស ជនគ ថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿ សាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយរួច ហើយ ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ (និងអ្នកបក ប្រែបើមាន) ហើយឲ្យចុះហត្ថលេខា ឬផ្តិតខ្មៅដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណី ដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតម្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុអំពីហេតុ ការណ៍នេះ ។

[9] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[10] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅ មន្ត្រីនគរបាលអាចស្នើសុំទៅ ព្រះរាជអាជ្ញាដើម្បីឲ្យចេញដីកាបញ្ជាឲ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឲ្យចូលបង្ហាញខ្លួនបាន [11]។

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អន់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញដែលមាន នៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ បើអ្នកជំនាញពុំស្ថិតនៅក្នុងបញ្ជីថ្នាក់ជាតិ អ្នកជំនាញនោះត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួននឹងជួយដោយភក្តីភាពដល់តុលាការ ។

### ១.២.៤. វិធានក្នុងការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិក្នុងការឃាត់ខ្លួននូវបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ក្រោយពីបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស បុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីបទល្មើស ឬដំណើររឿងហេតុ ក្នុងករណីដែលបុគ្គលនោះអាចផ្តល់ព័ត៌មានបានតែប្រកែកមិនព្រមផ្តល់ព័ត៌មាន ឬមានការយល់ព្រមអនុញ្ញាតដែលត្រូវបានឡើងជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

រយៈពេលនៃការឃាត់ខ្លួនមានចិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ក្នុងបទឧក្រិដ្ឋដែលតម្រុយភស្តុតាងបានបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ហើយវិធានការនៃការឃាត់ខ្លួនជាភាពចាំបាច់ដើម្បីធ្វើការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ហើយផុតរយៈដូចបានកំណត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំធ្វើការពន្យាពេល នៃការឃាត់ខ្លួនបុគ្គលនេះបន្ថែម តែមិនឲ្យលើសពី ២៤ ម៉ោងនោះទេ ហើយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ។ លិខិតដែលអនុញ្ញាតនេះត្រូវមានសំអាងហេតុ និងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។

ការពន្យាពេលនៃការឃាត់ខ្លួននេះ មិនអាចធ្វើការពន្យាពេលបានឡើយ ប្រសិនបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន ហើយរយៈពេលនៃការឃាត់ខ្លួនអនីតិជនអាចត្រូវធ្វើទៅបានក្នុងករណីដូចខាងក្រោមនេះ៖

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

[11] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ដោយឡែកអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនត្រូវបានធ្វើការឃាត់ខ្លួននោះទេ[12] ។

គ្រប់បុគ្គលដែលត្រូវបានឃាត់ខ្លួន មានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ដែលមេធាវី ឬ អ្នកដែលបុគ្គលត្រូវបានជ្រើសរើសដោយបុគ្គលដែលគេឃាត់ខ្លួន(បុគ្គលដែលពុំជាប់ពាក់ព័ន្ធនឹងរឿងក្តី)អាចធ្វើការសន្ទនាជាមួយនឹងបុគ្គលដែលត្រូវបានគេឃាត់ខ្លួនរយៈ ៣០ នាទី ក្នុងល័ក្ខខណ្ឌសំងាត់ក្រោយពេលដែលបុគ្គលនេះត្រូវបានគេឃាត់ខ្លួនរយៈ ២៨ ម៉ោងរួចមក [13]។

ចំពោះអនីតិជនដែលត្រូវបានឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការជូនដំណឹងដល់ឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកដែលទទួលភារកិច្ចលើអនីតិជននោះ ។ ការឃាត់ខ្លួនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីសរុបនៃការឃាត់ខ្លួនដាក់បញ្ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ[14] ។

### ១.២.៥.វិធាននៃការបញ្ជូនជនដែលត្រូវបាននឃាត់ខ្លួនដល់ព្រះរាជអាជ្ញា

ក្រោយពីផុតរយៈពេលនៃការឃាត់ខ្លួន ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា បើពុំនោះទេត្រូវដោះលែងជនដែលត្រូវបានឃាត់ខ្លួនឲ្យមានសេរីភាពឡើងវិញ ហើយសេចក្តីសម្រេចនៃការដោះលែងជនត្រូវឃាត់ខ្លួន ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា[15]។

ការបញ្ជូនខ្លួនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា មានន័យថាបុគ្គលនោះត្រូវបានគេនាំយកទៅបង្ហាញខ្លួនភ្លាមនៅចំពោះមុខព្រះរាជអាជ្ញា ។ ហើយករណីដែលការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានគេឃាត់ខ្លួនដែលត្រូវធ្វើការបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ពុំអាចធ្វើឡើងក្នុងថ្ងៃតែមួយបាននោះទេ ដោយសារមូល

[12] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[13] មាត្រា ៤៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[14] មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[15] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ហេតុលំបាកនៃការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកបញ្ជូន នោះរយៈពេលបន្ថែមអាចត្រូវបន្ថែមឲ្យដោយព្រះរាជអាជ្ញាបាន ។ ហើយការបង្ហាញខ្លួននេះត្រូវធ្វើឡើងក្នុងរយៈដ៏ឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន[16] ។

### ១.២.៦. វិធានពិសេសក្នុងការស៊ើបអង្កេតករណីជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចក្នុងការបង្គាប់ឲ្យស្តាប់និងថតសំលេងការសន្ទនាតាមទូរស័ព្ទ ថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ (ដូចជាសារតាមទូរសារ ឬតាមអិនធឺណេត) នោះឡើយ ។

ក្រោយពីរយៈពេលនៃការស៊ើបអង្កេតជាក់ស្តែងត្រូវបានបញ្ចប់ ឬ ការបញ្ចប់នៃការស៊ើបអង្កេតជាក់ស្តែងបានបញ្ចប់ហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនកំណត់ហេតុ រួមនឹងវត្ថុចាប់យកទាំងអស់ទៅព្រះរាជអាជ្ញា ហើយបុគ្គលដែលត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញាមន្ត្រីនគរបាលត្រូវធ្វើការបញ្ជូនទាំងមនុស្ស និងកំណត់ហេតុរួមនឹងវត្ថុតាងទៅផងដែរ ។[17]

មន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតជាក់ស្តែងខាងលើនេះទេដែលមាន៖

- កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការឆែកឆេរក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការបិទស្លាកបោះត្រាលើវត្ថុតាងក្នុងការស៊ើបអង្កេតជាក់ស្តែង
- កំណត់ហេតុលើស្តាប់ចម្លើយក្នុងការស៊ើបអង្កេតជាក់ស្តែង
- បទបញ្ជាឲ្យចូលខ្លួនក្នុងករណីស៊ើបអង្កេទបទល្មើសជាក់ស្តែង
- ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ
- កំណត់ហេតុស្តីពីការឃាត់ខ្លួន
- ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន
- ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង
- ថេរវេលានៃការស៊ើបអង្កេតជាក់ស្តែង

[16] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[17] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ និងនាំឲ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ[18] ។

## ១.៣. ការស៊ើបអង្កេតបឋម

ក្នុងករណីដែលបានដឹងអំពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងជាបឋម ឬ តាមការស្នើសុំ (បញ្ជា) របស់ព្រះរាជអាជ្ញា។ ចំពោះវិធានដែលទាក់ទងនឹងការស៊ើបអង្កេតនេះ វិធាននៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានយកមកអនុវត្តន៍។

### ១.៣.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទល្មើសមិនជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបានផងដែល ក្នុងករណីនៃវិធានស៊ើបអង្កេតមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម ។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានការយល់ព្រមដែលធ្វើឡើងដោយលាយល័ក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរនោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ ។

ហើយក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធន៍មិនឲ្យធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចធ្វើសំណើសុំដីកាអនុញ្ញាតឲ្យធ្វើការឆែកឆេរដែលចេញដោយប្រធានសាលាដំបូង ហើយការដឹកនាំនៃវិធានក្នុងការឆែកឆេរនេះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ។ ការឆែកឆេរនេះត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

ចំពោះការឆែកឆេរនេះ មិនអាចផ្តើមការឆែកឆេរនៅមុខម៉ោង ០៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ[19] ។

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់ (វត្ថុតាង) យកនោះ ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញ អ្នកកាន់កាប់ទី

[18] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[19] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កន្លែង ឬសាក្សីពីរនាក់មើលរួច ធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬ ផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងក្តីនេះបាន។ ការស្តាប់ចម្លើយ (សួរយកចម្លើយ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីដែលជនត្រូវបាន ស្តាប់ចម្លើយជាជនបរទេស ជនគ ថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយរួចហើយ ត្រូវអានដោយសម្លេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ (និងអ្នកបកប្រែបើមាន) ហើយឲ្យចុះហត្ថលេខា ឬផ្តិចខ្មៅដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណីដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិចស្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុអំពីហេតុការណ៍នេះ[20] ។ បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅនេះ មន្ត្រីនគរបាល អាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឲ្យចេញដីកាបញ្ជាឲ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន[21] ។

### ១.៣.២. វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន

វិធានពាក់ព័ន្ធនឹងការឃាត់ខ្លួន និងការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ក្នុងការស៊ើបអង្កេតជាក់ស្តែង ត្រូវបានយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋម ។

### ១.៣.៣. វិធានពិសេសក្នុងការស៊ើបអង្កេតករណីបឋម

មន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតបឋមខាងលើនេះទេដែលមាន៖

- ការឃាត់ខ្លួន
- កំណត់ហេតុនៃការឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង

[20] មាត្រា ១១៤ និងមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[21] មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា
- ការឆែកឆេរ
- ការបញ្ជាឲ្យចូលខ្លួន

និងនាំឲ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ[22] ។

## ផ្នែកទី២ ដំណាក់កាលអយ្យការ

ចំពោះការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ ។ ការចោទប្រកាន់ធ្វើឡើងតាមរយៈបណ្ដឹងអាជ្ញា ។ ដោយអនុលោមតាម ១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។ ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ដូចនេះព្រះរាជអាជ្ញាអាចចុះទីកាន់ទីកន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ ហើយអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំឲ្យមានអ្នកជំនួស ។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ច បានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌អាចចូលរួមស្ដាប់ចម្លើយត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ។ ក្រៅពីនេះ ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌនេះ បានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។ ព្រះរាជអាជ្ញារងដែលក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើអំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស ។

ក្រៅពីអំណាចដឹកនាំសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ អំណាចនៃការបើកការស៊ើបអង្កេត ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើបណ្ដឹងអាជ្ញាឲ្យមានចលនាមានន័យថា ការចោទប្រកាន់ពីបទល្មើសណាមួយ ។

### ២.១. អង្គការអយ្យការ

#### ២.១.១. អំណាចរបស់អង្គការអយ្យការ

អង្គការអយ្យការ ឬស្ថាប័នអយ្យការដែលអមតុលាការខេត្ត-រាជធានី មានតួនាទីក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាកោះហៅបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឲ្យចូលបង្ហាញខ្លួនភ្លាម ដីកាសន្និដ្ឋានស្ថាពរ និងការធ្វើ

---

[22] មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សេចក្ដីថ្លែងការប្ដឹងសុំដោយផ្ទាល់មាត់នៅដំណាក់កាលជំនុំជម្រះ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្ត សេចក្ដីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ មានន័យថាស្ថាប័នអយ្យការ មានតួនាទីអនុវត្តនូវសេចក្ដីសម្រេចដែលធ្វើឡើងដោយចៅក្រម ។

**ឧទាហរណ៍**: ការអនុវត្តសាលក្រមតុលាការ ការអនុវត្តន៍ការចាប់ខ្លួនតាមដីកាចាប់ខ្លួន ការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនជាដើម[23] ។

ចៅក្រមអយ្យការពេលបំពេញភារកិច្ចរបស់ខ្លួនមានសិទ្ធិអំណាចក្នុងការកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន ។

នៅពេលសវនាការចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងក្ដីព្រហ្មទណ្ឌ ការដែលអវត្តមានតំណាងអយ្យការ នាំឲ្យមានមោឃភាពនីតិវិធី ។

## ២.១.២. ឋានុក្រមនៃចៅក្រមអយ្យការ

ចៅក្រមអយ្យការត្រូវបានកំណត់នៅឋានុក្រមដូចខាងក្រោមនេះ[24]៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃស្ថាប័នមហាអយ្យការយ្យការអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទីក្នុងការចូលរួមក្នុងការស្នើសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្ដឹងសារទុក្ខ បណ្ដឹងសើរើ និងបណ្ដឹងតវ៉ាផ្សេងៗទៀត ដែលដាក់ជូនតុលាការកំពូលពិនិត្យ[25] ។

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជាតំណាងស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចនៅអង្គភាពអយ្យការទាំងឡាយដែលស្ថិតនៅក្រោមសមត្ថកិច្ចដែន

[23] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[24] មាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[25] មាត្រា ៣១ និងមាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដីរបស់ខ្លួន ។ ក្នុងករណីដែលមានបទល្មើសធ្ងន់ធ្ងរកើតឡើង ព្រះរាជអាជ្ញាត្រូវធ្វើការរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[26] ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងការត្រួតពិនិត្យនគរបាលយុត្តិធម៌ ។

អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តិទៅរបស់អង្គភាពនគរបាលទាំងនេះ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌។

អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួនជាពិសេសគឺគោរពទម្រង់ច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន ។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន[27] ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង គឺជាតំណាងរបស់អង្គភាពអយ្យការអមតុលាការ[28] ។ ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណាអនុវត្តដីកាឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាច ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌។ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌អនុវត្តអំណាចទាំងអស់ដែលព្រះរាជអាជ្ញាបានផ្តល់ឲ្យ។ ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតរបស់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ហើយរៀបចំជំនួសមន្ត្រីនិងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការពទម្រង់ច្បាប់ និងការកាន់

[26] មាត្រា ៣៣ និងមាត្រា ៣៤ នៃក្រមនីវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[27] មាត្រា ៣៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[28] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កាប់ទីកន្លែងឃាត់ខ្លួន[29] ។ ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ។

នៅពេលមានពាក្យបណ្ដឹងបរិហារដែលបានប្ដឹងចូលមកស្ថាប័នអយ្យការដោយផ្ទាល់ ឬពាក្យបណ្ដឹងដែលទទួលបានដោយមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹង ដែលនាំឲ្យមានការចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការនូវបទល្មើសព្រហ្មទណ្ឌ ។ ហើយមុននឹងធ្វើចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម[30] ។

## ២.១.៣. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

នៅមុនពេលអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ការចោទប្រកាន់របស់អង្គការអយ្យការត្រូវ បានគេជ្រើសរើសតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ។

គោលការណ៍នេះមានន័យថាកាលណារឿងព្រហ្មទណ្ឌមួយត្រូវបានប្ដឹងមកមន្ទីរអយ្យការ ព្រះរាជអាជ្ញាត្រូវតែសម្រេចចាត់ការបណ្ដឹងនោះឲ្យតែបទល្មើស ដែលត្រូវបានប្ដឹងនោះមានធាតុផ្សំខាងអង្គហេតុ និងអង្គច្បាប់គ្រប់គ្រាន់ដោយព្រះរាជអាជ្ញាមិនត្រូវគិតដល់កាលៈទេសៈអ្វីផ្សេងទៀតទេ។ គោលការណ៍នេះមានប្រភពចេញពីគោលការណ៍ដែលថា គ្មានបទល្មើសដែលគ្មានច្បាប់បង្ក្រាប និងគ្មានទោស ដោយគ្មានទោសបញ្ញត្តិ ។

## ២.១.៤. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

ក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ត្រូវបានអនុវត្ត គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់មិនត្រូវបានគេលើកយកមកអនុវត្តទៀតនោះទេ ដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានលើកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកអនុវត្តជំនួសវិញ ។

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលត្រូវបានបញ្ចូលនៅក្នុងក្រមនីតិវិធីថ្មីនេះ ជាយន្តការទំនើបកម្មនៃនីតិក្នុងបរិបទកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។ គោលការណ៍នេះស្របទៅនឹងចរន្តពិភពលោកដែលកំពុងមានការផ្ដោតអារម្មណ៍ និងយកចិត្តទុកដាក់ ហើយកំពុងត្រូវបានអនុវត្តនៅតាមបណ្ដាប្រទេសជឿនលឿន ។

[29] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[30] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ការអនុវត្តគោលការណ៍នេះ ត្រូវបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ដែលជាគោលការណ៍មួយពុំធ្លាប់ត្រូវបានអនុវត្តនៅកម្ពុជានាពេលកន្លងមកនោះទេ គោលការណ៍ដែលត្រូវបានអនុវត្តនៅប្រទេសកម្ពុជាចាប់តាំងពីពេលដែលមាននីតិព្រហ្មទណ្ឌនាយុគ្គសម័យមុនៗ រហូតមកដល់មុនពេលអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ គឺប្រទេសកម្ពុជាបានអនុវត្តគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដោយតាមរយៈនេះស្ថាប័នទទួលបន្ទុកចោទប្រកាន់នូវរឿងក្តីព្រហ្មទណ្ឌត្រូវបានចាប់បង្ខំដោយនីតិឲ្យធ្វើការចោទប្រកាន់គ្រប់រឿងក្តីទាំងឡាយដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌដោយមិនគិតអំពីស្ថានភាពនៃបទល្មើស ឬបរិបទសង្គម ឬតាមរបៀបមនុស្សធម៌នោះទេ ។ ផ្ទុយមកវិញ គោលការណ៍ថ្មីខាងលើនេះ ស្ថាប័នចោទប្រកាន់បទល្មើស ត្រូវបានផ្តល់ឲ្យដោយច្បាប់នូវអំណាចនៃជម្រើសក្នុងការចោទប្រកាន់ទោះបីជាអង្គហេតុទាំងនោះមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ។ ប៉ុន្តែអំណាចដែលផ្តល់ឲ្យដោយច្បាប់នេះពុំមានស្ថានភាពទូលំទូលាយហួសហេតុដែលអាចធ្វើបានតាមទំនើងចិត្តទេត្រូវបានកម្រិតដោយលក្ខខណ្ឌគតិយុត្តមួយចំនួន ។

គោលការណ៍នេះ ត្រូវបានវិស័យនីតិនិពន្ធតាក់តែងឡើងដើម្បីបង្កើតនូវវិធានកណ្តាលនៃការចោទប្រកាន់ដោយប្រគល់ឲ្យស្ថាប័នចោទប្រកាន់ ពោលគឺស្ថាប័នអយ្យការនូវជម្រើសដ៏សំខាន់ក្នុងការធ្វើចំណាត់ការសំណុំរឿងក្តីព្រហ្មទណ្ឌ ។ តាមរយៈគោលការណ៍នេះអនុញ្ញាតឲ្យស្ថាប័នអយ្យការមានជម្រើសមិនធ្វើការចោទប្រកាន់ ទោះបីអំពើដែលបរិហារនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ។ ជម្រើសមិនចោទប្រកាន់នេះសម្តែងចេញតាមការរយៈសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការ ផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ដូចគ្នាដែរ ក្នុងករណីដែលមានអំពើច្រើនដែលត្រូវ បានប្តឹងមកនោះមានការពាក់ព័ន្ធក្នុងអង្គហេតុមួយ ព្រះរាជអាជ្ញាមានជម្រើសធ្វើការចោទប្រកាន់នៅអំពើណាមួយ ហើយមិនចោទប្រកាន់នូវអំពើផ្សេងទៀត ។ គោលការណ៍នេះ ក៏បានអនុញ្ញាតឲ្យស្ថាប័នអយ្យការនូវសេរីភាព ក្នុងការជ្រើសរើសមធ្យោបាយធ្វើបណ្តឹងអាជ្ញាកាលបើច្បាប់មិនបានចែងថា ការបើកការស៊ើបសួរតាមផ្លូវយុត្តាធិការស៊ើបសួរមានលក្ខណៈដាច់ខាតនោះទេ។

**ឧទាហរណ៍**: មានករណីមួយដែលជនល្មើសជាជនដែលមានជីវភាពក្រីក្រ គាត់បានលួចបេះផ្លែស្វាយរបស់អ្នកភូមិមួយ ដើម្បីចម្អែតក្រពះ ។ តាមរយៈសកម្មភាពរបស់ជនល្មើសបានឆ្លើយតបនឹងនិយមន័យនៃអំពើលួចតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ដែលចែងថាៈ អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ បើយើងអនុវត្តតាមគោលការណ៍នីត្យានុកូលនៃការចោទប្រកាន់ជនល្មើសនេះនឹងត្រូវចោទប្រកាន់ដោយ ស្ថាប័នអយ្យការ ក៏ប៉ុន្តែបើយើងអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញដោយផ្អែកតាមស្ថានភាពរបស់ជនល្មើស ព្យាសនកម្មនៃអំពើល្មើសវិញនោះ ជនល្មើសនេះអាចត្រូវបានស្ថាប័នអយ្យការតម្កល់រឿងទុកឥតចាត់ការបាន ។

## ២.២. ការធ្វើបណ្តឹងអាជ្ញា

### ២.២.១. ជម្រើសការចោទប្រកាន់

ការអនុវត្តន៍តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង នីតិវិធីដែលរួចរាល់ អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬផ្ទុយទៅវិញ តម្រូវឲ្យមានការស៊ើបសួរទូលំទូលាយ ពោល គឺអាចប្ដឹងទៅយុត្តាធិការជំនុំជម្រះ ឬប្ដឹងទៅយុត្តាធិការស៊ើបសួរ ។ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមមធ្យោបាយពីរជាអាទិ៍ ៖

១-ការប្ដឹងទៅយុត្តាធិការស៊ើបសួរ គឺការបើកធ្វើការស៊ើបសួរ

២-ការប្ដឹងទៅយុត្តាធិការជំនុំជម្រះ ប្ដឹងតាមរបៀបពីរ គឺ៖

- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[31] ។

### ២.២.២. ការបើកការស៊ើបសួរ

ដោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាប្ដឹងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺ ៖

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស (ឧទាហរណ៍ ៖ អំពើលួច ឃាតកម្ម ជាដើម)
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (ក្នុងករណីមិនអាចកំណត់បានអាចបើការស៊ើបសួរប្រឆាំងនឹងអញ្ញាតជន ពោលគឺជនមិនស្គាល់)។
- ចុះកាលបរិច្ឆេទ និង ហត្ថលេខា ។

ព្រះរាជអាជ្ញាមានកាតព្វកិច្ចធ្វើដីកានេះស្នើឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរក្នុងករណីដូចខាងក្រោម៖

- បទល្មើសឧក្រិដ្ឋជាក់ស្ដែង ឬមិនជាក់ស្ដែង ។
- បទល្មើសមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថាត្រូវបើការស៊ើបសួរ ។

[31] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- **បញ្ជូនទៅជំនុំជម្រះផ្ទាល់**

ក្នុងករណីនេះ ព្រះរាជអាជ្ញាចេញដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចធ្វើបានតែចំពោះបទល្មើសមជ្ឈិម (មាត្រា ៤៥ នៃក្រម) និង បទល្មើសលហុ (មាត្រា ៤៩ នៃក្រម) ប៉ុណ្ណោះ ។

- **នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

ប្រសិនបើលក្ខខណ្ឌនៃ មាត្រា ៤៧ នៃនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញព្រះរាជអាជ្ញាអាចប្រើប្រាស់នីតិវិធីនេះបានដោយគ្រាន់តែធ្វើកំណត់ហេតុប៉ុណ្ណោះ ពុំមានចេញដីកាសន្និដ្ឋានអ្វីទេ ។ លក្ខខណ្ឌដែលអាចឱ្យប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបានមាន ៖

- បទមជ្ឈិមជាក់ស្ដែង ។
- បទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និង យ៉ាងច្រើន ៥ ឆ្នាំ ។ ហេតុនេះ ប្រសិនបើជនល្មើសត្រូវចោទប្រកាន់ពីបទប្រើប្រាស់គ្រឿងញៀន នីតិវិធី នៃការបង្ហាញខ្លួនភ្លាមមិនអាចយកមកប្រើប្រាស់បានឡើយ ។
- ជនជាប់ចោទជានីតិជន ។
- រឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**ឧទាហរណ៍** ៖ បទបើកកន្លែងលេងល្បែងស៊ីសង បទបើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា អំពើលួចជាដើម ។

ក្នុងដំណាក់កាលនេះកាលបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងនីតិវិធីអាចបញ្ជូនទៅតុលាការ ជំនុំជម្រះដោយពុំចាំបាច់មានការស្រាវជ្រាវផ្សេងទៀត ។ ស្ថានភាពនៃសំណុំរឿងនីតិវិធីនេះត្រូវបានសន្មត់ជាដំបូងថាគេបានសង្ស័យទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដែលបានកំណត់អត្តសញ្ញាណ ហើយត្រូវបានស្ដីបន្ទោសពីបទល្មើសមួយឬច្រើនដែលបទល្មើសទាំងនោះជាបទល្មើសមជ្ឈិម ឬបទលហុ ។ ការប្ដឹងទៅយុត្តាធិការជំនុំជម្រះព្រះរាជអាជ្ញាអាចសម្រេចឲ្យបុគ្គល ដែលពាក់ព័ន្ធមកបង្ហាញខ្លួននៅចំពោះមុខដើម្បីធ្វើការចោទប្រកាន់ភ្លាមៗ តាមរយៈមធ្យោបាយពីរ គឺការចូលបង្ហាញខ្លួនភ្លាម ឬដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ប៉ុន្តែវិធាននៃនីតិវិធីបែបនេះមិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋនោះទេ ។

វិធីចំណាត់ការបែបនេះ អនុញ្ញាតឲ្យព្រះរាជអាជ្ញាប្ដឹងដោយផ្ទាល់ទៅយុត្តាធិការជំនុំជម្រះ និងបង្គាប់ឲ្យជនជាប់ចោទបង្ហាញខ្លួននៅមុខសាលាដំបូង ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ អាចអនុវត្តចំពោះគ្រប់បទមជ្ឈិម និងបទលហុ តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកានេះត្រូវចុះនូវអត្តសញ្ញាណជនជាប់ចោទ សេចក្ដីសង្ខេបអង្គហេតុ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសព្រមទាំងការចង្អុលបង្ហាញប្រាប់ពីតុលាការដែលទទួលបណ្ដឹង ទីកន្លែង កាលបរិច្ឆេទ ម៉ោងពេលនៃសវនាការ និងជាចុងក្រោយនៃដីកានេះ

ត្រូវបញ្ជាក់ឲ្យបានច្បាស់ថា ជនជាប់ចោទអាចសុំជំនួយពីមេធាវីឲ្យអមខ្លួនបាន ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាដល់ជនជាប់ចោទឲ្យចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូងដែលសម្រេចពីរឿងក្តីព្រហ្មទណ្ឌ ។

យោងតាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិអំពីការកំណត់កាលបរិច្ឆេទនៃសវនាការដែលត្រូវកំណត់ដោយប្រធានតុលាការ (លើកលែងតែនីតិវិធីបង្ហាញខ្លួនភ្លាម) ។ នៅក្នុងករណីដែលតុលាការបានទទួលបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬដោយសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលចែងក្នុងមាត្រា ៤៥៧ និងមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ ។

រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ [32]៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការតុលាការជាន់ដំបូង ។
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ ។
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា ។
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត ។

ចិរវេលាខាងលើនេះត្រូវតែគោរពបើពុំដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធីនៃការកោះហៅ លើកលែងតែជនជាប់ចោទយល់ព្រមចូលខ្លួនមកបង្ហាញដោយស្ម័គ្រចិត្ត ។

ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទអាចធ្វើឡើងដោយ ព្រះរាជអាជ្ញា ឬអាជ្ញាសាលា ឬមេឃុំ-ចៅសង្កាត់ ឬអនុប្រធាន បើសិនជាជនជាប់ចោទបដិសេធមិនទទួលដីកា និងជាចុងក្រោយការប្រគល់ដីកា អាចធ្វើដោយក្រឡាបញ្ជីតាមផ្លូវរដ្ឋបាលដោយប្រធានពន្ធនាគារ ឬអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ហើយវិធីនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ មានបញ្ញត្តិដោយមាត្រា ៤៤៨ និងបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ភាគីដែលត្រូវកោះហៅនៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវបានបញ្ញត្តិដោយមាត្រា ២៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះការកោះហៅត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាឲ្យចូលរួមសវនាការនូវ៖ ជនរងគ្រោះ សាក្សី អ្នកបកប្រែ(បើចាំបាច់) អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ឲ្យដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

[32] មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

វិធីនៃការកោះហៅភាគីនៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ត្រូវអនុវត្តដូចដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ។

### ២.២.៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនផ្ទាល់

វិធីចំណាត់ការបែបនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាបង្គាប់ ឲ្យជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមៗនៅមុខសាលាដំបូង បន្ទាប់ពីបញ្ចប់ការឃាត់ខ្លួនប៉ុន្តែវិធាននៃនីតិវិធីនេះមិនត្រូវបានអនុវត្តចំពោះបទលហុ និងបទមជ្ឈិមដែលប្រព្រឹត្តដោយអនីតិជននោះទេ ។ លើសពីនេះវិធាននេះអាចអនុវត្តបានលុះត្រាតែ គោរពលក្ខខណ្ឌមួយចំនួន ពោលគឺ ប្រភេទចំណាត់ការសំណុំរឿងបែបនេះ អាចធ្វើបានតែក្នុងករណីបទមជ្ឈិមជាក់ស្តែងដែលមានទណ្ឌកម្មនៃទោសដាក់ពន្ធនាគារដែលត្រូវសម្រេចដោយតុលាការយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ ។

នីតិវិធី ពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនដោយមានកម្លាំងការពារដើម្បីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ។ បន្ទាប់ពីបានទទួលកំណត់ហេតុ និងខ្លួនបុគ្គលឃាត់ខ្លួនពីមន្ត្រីនបាលយុត្តិធម៌ កាលបើសម្រេចច្រើននីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ ៖

- ពិនិត្យ ឬសាកសួរអំពីអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស ព្រមទាំងអត្ថបទច្បាប់កំណត់ និងបង្ក្រាបបទល្មើស ។
- ទទួលស្តាប់យកចម្លើយរបស់សាមីជន ប្រសិនបើជននោះចង់និយាយ ដោយប្រាប់ទៅជននេះថា ក្រោមវិធានបង្គាប់បែបនេះ ជននេះនឹងត្រូវជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្តងដោយសាលាដំបូង ហើយមានសិទ្ធិទទួលជំនួយ ពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬតាមការចាត់តាំងឡើងដោយ អនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ទាប់ពីបានទទួលការជ្រើសរើស ឬចាត់តាំងរួចហើយ មេធាវីត្រូវបានទទួលដំណឹងភ្លាម ហើយមានសិទ្ធិអាចពិនិត្យសំណុំរឿង និងទំនាក់ទំនងជាមួយជនជាប់ចោទបាន ។
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលខ្លួនភ្លាម។ការឲ្យដំណឹងអំពីការបង្គាប់ដែលធ្វើឡើងដោយកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមគឺជាដីកាកោះប្រគល់ឲ្យជនត្រូវចោទដែលក្នុងខណៈនោះ ជនត្រូវចោទត្រូវបានទទួលឈ្មោះថា ជាជនជាប់ចោទ ។
  ទម្រង់ការទាំងនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ បើពុំនោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

ជនជាប់ចោទត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពាររហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

សាលាដំបូងដែលទទួលបណ្តឹងតាមកំណត់ហេតុត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទដំបូងគេបង្អស់ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ជាពិសេសត្រូវប្រាប់ដល់ជននេះ អំពី

រយៈពេលដែលមានដើម្បីរៀបចំការពារខ្លួន ។ ការទាមទារបែបនេះ បង្ហាញឲ្យឃើញច្បាស់ដោយសារជនជាប់ចោទពុំមានរយៈពេលដើម្បីរៀបចំការពារខ្លួនចាប់តាំងពីពេលទទួលដំណឹងអំពីការបង្គារ ។ ប្រសិនបើជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ឬបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ នោះសំណុំរឿងត្រូវលើកទៅពេលសវនាការនាពេលក្រោយ ។ សវនាការនេះត្រូវបើកក្នុងថិរវេលាមិនអាចលើសពីពីរសប្ដាហ៍បានឡើយ ។ ក្នុងរយៈពេលដែលរង់ចាំការបង្ហាញខ្លួន តុលាការត្រូវសម្រេចគួរឃុំខ្លួនជនជាប់ចោទដោយសាលក្រម ដែលមានបញ្ជាក់ពីសំអាងហេតុយោងអំពីមូលហេតុនៃការឃុំខ្លួនជាបណ្ដោះអាសន្នតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាបណ្ដោះអាសន្នរហូតដល់ពេលសវនាការ ។ បន្ទាប់មកតុលាការ ត្រូវចេញដីកាសម្រេចបង្គាប់ឲ្យឃុំខ្លួនយោងតាមអំណាចសាលក្រម ។

កាលបើរយៈពេលពីរសប្ដាហ៍គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការកន្លងផុតទៅសាលក្រមលើអង្គសេចក្ដីនៅមិនទាន់បានប្រកាសនោះការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ។

ការអនុវត្តវិធាននៃនីតិវិធីបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា មិនមានអានុភាពកម្រិតឲ្យសាលាដំបូងត្រូវតែប្រតិបត្តិនោះទេ ផ្ទុយទៅវិញ តុលាការមានសេរីភាពវាយតម្លៃលើស្ថានភាពនៃសំណុំរឿងនីតិវិធី និងអាចសន្និដ្ឋានជាយថាហេតុកាលបើលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានបំពេញទេ ឬក៏រឿងក្ដីនេះមានភាពសាំញ៉ាំ តម្រូវជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវឲ្យបានជ្រាលជ្រៅបន្ថែមតុលាការត្រូវបញ្ជូនរឿងនោះ ទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។ ជនត្រូវចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្ដងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនត្រូវចោទត្រូវតែដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង ។

ភាគីដែលត្រូវកោះហៅនៅក្នុងករណីចូលបង្ហាញខ្លួនភ្លាមដែលក្នុងនោះ ការកោះហៅត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាឲ្យចូលរួមសវនាការនូវ[33] ជនរងគ្រោះ សាក្សី អ្នកបកប្រែ(បើចាំបាច់) អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្ដល់ឲ្យដោយជនជាប់ចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ។

វិធីនៃការកោះហៅភាគីនៅក្នុងករណីចូលបង្ហាញខ្លួនភ្លាមត្រូវអនុវត្តដូចដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ប៉ុន្តែក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមគ្រប់មធ្យោបាយ ទោះបីដោយផ្ទាល់មាត់ក៏ដោយ ។

[33] ២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.២.៥. ការតម្កល់រឿងទុកឥតចាត់ការ

ជម្រើសមិនចោទប្រកាន់ត្រូវបានសម្ដែងចេញតាមរយៈសេចក្ដីសម្រេចតម្កល់រឿងទុកមិនចាត់ការ ដែលផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ពោលគឺថា ការតម្កល់ទុកឥតចាត់ការ គឺជាអំណាចផ្ដាច់មុខរបស់ព្រះរាជអាជ្ញា ដោយហេតុថា អធិបញ្ញាតាមគោលការណ៍ឋានានុក្រមនៃអង្គការអយ្យការនោះ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាឲ្យធ្វើការចោទប្រកាន់ប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើអធិបញ្ញាឲ្យតម្កល់ទុកមិនចាត់ការនូវរឿងក្ដីណាមួយបានឡើយ ។

មូលហេតុនៃការតម្កល់រឿងទុកមិនចាត់ការមានច្រើន និងមិនបានកំណត់ដោយច្បាប់នោះទេ ។ ការតម្កល់រឿងទុកមិនចាត់ការអាចមានមូលហេតុមកពីអវត្តមាននៃអត្តសញ្ញាណរបស់ចារី អវត្តមាននៃបទល្មើស ឬពុំមានបន្ទុកគ្រប់គ្រាន់ ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដែលអាចនឹងត្រូវធ្វើហាក់ដូចជាគ្មានប្រយោជន៍ និងគ្មានប្រសិទ្ធភាព ការផុតរលត់នៃបណ្ដឹងអាជ្ញា ។ ការតម្កល់រឿងទុកមិនចាត់ការនេះក៏អាចមានមូលហេតុមកពីនត្ថិភាពនៃបទល្មើស ឬបទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ជាអាទិ៍ ធាតុនៃសំណុំរឿងមិនអនុញ្ញាតឲ្យកំណត់ពីធាតុផ្សំបទល្មើសដែលរាយការណ៍មក ។

ជាចុងក្រោយចំណុចដែលឆ្លើយតបទៅនឹងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺការតម្កល់រឿងទុកមិនចាត់ការអាចធ្វើឡើងទោះបីជាអំពើដែលប្ដឹងមកនោះជាបទល្មើស ហើយអ្នកប្រព្រឹត្តបទល្មើសត្រូវបានគេស្គាល់មុខ ប៉ុន្តែស្ថាប័នអយ្យការយល់ថា ការតម្កល់រឿងទុកនេះត្រូវតាមកាលៈទេសៈ ព្រោះព្យសនកម្មដែលកើតមានដោយសារបទល្មើស ឬភាពរំខានដល់សណ្ដាប់ធ្នាប់សាធារណៈមានចរិតលក្ខណៈមិនធ្ងន់ធ្ងរ ឬដោយស្ថានភាពបុគ្គលិកលក្ខណៈរបស់ចារីឬអត្តចរិករបស់ជនរងគ្រោះ ។

ការតម្កល់រឿងទុកមិនចាត់ការត្រូវធ្វើឡើងដោយសេចក្ដីសម្រេចដែលមានសំអាងហេតុ និងសំអាងច្បាប់ ហើយសេចក្ដីសម្រេចនេះពុំមានអានុភាពជាអាជ្ញាអស់ជំនុំនោះទេ ។ ស្ថាប័នអយ្យការមានសិទ្ធិអំណាចសើរើសំណុំរឿងនេះដោយចាប់ផ្ដើមស៊ើបអង្កេតឡើងវិញ ឬធ្វើបណ្ដឹងអាជ្ញាបានគ្រប់ពេល ដរាបណាអាជ្ញាយុកាលនៃបណ្ដឹងមិនទាន់ផុតរលត់នៅឡើយ ។ សេចក្ដីសម្រេចតម្កល់រឿងទុកមិនចាត់ការ មិនអាចចៀសផុតពីការប្ដឹងតវ៉ានោះទេ ។ ហេតុនេះហើយទើបបទប្បញ្ញត្តិនៃក្រមនេះបានកំណត់ឲ្យស្ថាប័នអយ្យការជូនដំណឹងអំពីការតម្កល់រឿងទុកមិនចាត់ការរបស់ខ្លួនទៅអ្នកប្ដឹងហើយក្នុងចិរវេលា ២ ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចនេះ អ្នកប្ដឹងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេច អាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។ បន្ទាប់ពីបានទទួលបណ្ដឹងតវ៉ា សំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង ។

កាលបើអគ្គព្រះរាជអាជ្ញាយល់ឃើញថា បណ្ដឹងតវ៉ាមានមូលហេតុត្រឹមត្រូវនោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញាជាលាយលក្ខណ៍អក្សរដល់ព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ ប៉ុន្តែ ក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាតម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ រួចហើយអគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីសេចក្ដីសម្រេចនេះទៅអ្នកប្ដឹងតវ៉ា ។

### ២.២. ៦. ការដាក់បណ្ដឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ

ជាទូទៅបណ្ដឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនា និងអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ពីព្រោះអយ្យការជាអ្នកធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ប៉ុន្តែយោងតាមមាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាករណីអញ្ញត្រកម្មដោយបណ្ដឹងអាជ្ញាអាចត្រូវបានដាក់ឲ្យមានចលនាដោយជនរងគ្រោះផងដែរ ពោលគឺការដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ មានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរអំពីបណ្ដឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា ១៣៩ និង មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ជាគោលការណ៍បណ្ដឹងនេះ គឺជាសេរីភាពឆន្ទៈបុគ្គលឯកជន ។ ការដាក់ពាក្យបណ្ដឹងបែបនេះទាមទារឲ្យជនរងគ្រោះពិចារណាឲ្យបានល្អិតល្អន់បំផុតដោយហេតុថា បណ្ដឹងនេះអាចនឹងទទួលរងនូវប្រតិកម្មតបវិញ ដោយអ្នកប្ដឹងអាចនឹងប្រឈមនឹងការពិន័យរដ្ឋប្បវេណី និងបណ្ដឹងឲ្យជួសជុលការខូចខាតពីភាគីម្ខាងទៀត ក្នុងករណីដែលរកឃើញថាបណ្ដឹងនោះធ្វើឡើងដោយរំលោភបំពាន ឬបណ្ដឹងអូសបន្លាយពេលវេលា ។ ហេតុផលនេះហើយទើបមានការសន្មតថាបណ្ដឹងនេះអាចជាជម្រើសចុងក្រោយរបស់ជនរងគ្រោះ អាចនិយាយឲ្យកាន់តែច្បាស់ថែមទៀតនោះគឺបណ្ដឹងបែបនេះភាគច្រើនជនរងគ្រោះធ្វើឡើងបន្ទាប់ពីការតម្កល់ទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ឬបន្ទាប់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្ដីសម្រេចតម្កល់ឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ក្នុងក្របខ័ណ្ឌជំរុញឲ្យបណ្ដឹងអាជ្ញាមានចលនាចំពោះអង្គហេតុណាមួយដែល ជនរងគ្រោះយល់ឃើញថាខ្លួនបានទទួលរងការបំពានពីអំពើនោះ ហើយអំពើនោះទៀតសោតមានចរិកលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ។

**នីតិវិធី៖**កាលណាចៅក្រមស៊ើបសួរបានទទួលពាក្យប្ដឹងសុំ ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្ដឹងនោះដោយដីកា ហើយបញ្ជូនពាក្យនោះទៅព្រះរាជអាជ្ញា ។

ក្រោយពីបានទទួលពាក្យបណ្ដឹងនោះព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនចងកាតព្វកិច្ចឲ្យព្រះរាជ

អាជ្ញាត្រូវតែបើកឲ្យស៊ើបសួរចំពោះបុគ្គលដែលមានចង្អុលបង្ហាញក្នុងពាក្យប្តឹងនោះទេ បានសេចក្តីថាព្រះរាជអាជ្ញាអាចបើកឲ្យស៊ើបសួរប្រឆាំងនឹងអញ្ញាតជនទោះបីជា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ នៅក្នុងក្របខ័ណ្ឌនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរបានតែក្នុងករណីដែល៖

- បណ្តឹងអាជ្ញាត្រូវបានផុតរលត់
- អំពើដែលប្តឹងមកនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ ។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរតាមការប្តឹងសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ កាលបើអ្នកប្តឹងសុំមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា ។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។បន្ទាប់ពីបានសម្រេចស៊ើបសួរចៅក្រមស៊ើបសួរត្រូវកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ និងរយៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ។ ការសម្រេចកំណត់ចំនួនទឹកប្រាក់តម្កល់នេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យពិចារណា ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ។ កាលបើមិនឯកភាពតាមចំនួនទឹកប្រាក់ដែលកំណត់ដោយចៅក្រមស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា ។ កាលបើបានទទួលដំណឹងអំពីការកំណត់ឲ្យបង់ប្រាក់តម្កល់រួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវទៅបង់ប្រាក់ ដោយមានទទួលបង្កាន់ដៃ ដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ប៉ុន្តែក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណី ខកខានមិនបង់ប្រាក់ក្នុងរយៈពេលកំណត់ទេនោះ ចៅក្រមស៊ើបសួរត្រូវប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីនោះដោយដីកាសម្រេច ហើយត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីជាបន្ទាន់ ។ ក្នុងករណីនេះដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍បាន ក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា ។

ប្រាក់តម្កល់ទុកត្រូវរក្សាទុកនៅក្នុងគណនីពិសេសដែលបើកនៅក្នុងធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខរឹងមាំ ដែលត្រូវជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធាន និងព្រះរាជអាជ្ញា។ ប្រាក់តម្កល់ត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី លើកលែងក្នុងករណីដែលរកឃើញថាបណ្តឹង នេះធ្វើឡើងដោយបំពាន ឬអូសបន្លាយពេលវេលា ដែលត្រូវអនុវត្តបទប្បញ្ញត្តិនៃមាត្រា ១៤១ ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាច សម្រេចតាមដីកាលើកលែងមិនឲ្យបង់ប្រាក់តម្កល់នេះបាន ហើយជូនដំណឹងជាបន្ទាន់ទៅដើមបណ្តឹងរដ្ឋប្បវេណី។

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយកាលបើចៅក្រមស៊ើបសួរយល់ ឃើញថានីតិវិធីធ្វើឡើងដោយរំលោភបំពាន ឬអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី (ពិន័យស៊ីវិល = ទណ្ឌកម្មខាងហិរញ្ញវត្ថុមួយប្រភេទ ដែលកំណត់ឲ្យអ្នកប្រព្រឹត្តខុសនឹងបញ្ញត្តិនៃច្បាប់ផ្នែករដ្ឋប្បវេណីបង់ពិន័យ) ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ហើយដីកាសម្រេចឲ្យបង់ប្រាក់ពិន័យនេះ ត្រូវជូនដំណឹងដល់សាមីខ្លួនជាបន្ទាន់ ។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្តអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបានជូនដំណឹងពីដីកា ។

នៅពេលដែលបិទការស៊ើបសួរដោយដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរហើយនីតិវិធីធ្វើឡើងដោយរំលោភ ឬអូសបន្លាយពេលវេលា បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអាចដាក់ពាក្យប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងពីខ្លួនទៅតុលាការជាន់ដំបូងដែលស៊ើបសួររឿងក្តីនោះ ។

# ជំពូកទី២

# ដំណាក់កាលស៊ើបសួរ

# ជំពូកទី២
# ដំណាក់កាលស៊ើបសួរ

## ផ្នែកទី១ យុត្តាធិការស៊ើបសួរ

### ១.១ចៅក្រមស៊ើបសួរ

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជណាចក្រកម្ពុជា ចៅក្រមស៊ើបសួរ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្វែងរកការពិត ។ តួនាទីយ៉ាងមានសារៈសំខាន់របស់ ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ដែលជាសេចក្តីសម្រេច មានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល ។

#### ១.១.១. សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរគឺ ត្រូវមានតាមសាលាដំបូងរាជធានីខេត្តទាំងអស់នៅទូទាំងប្រទេស។ ដូច្នេះចៅក្រមស៊ើបសួរគាត់អាចបើកការស៊ើបសួរតែក្នុងដែនសមត្ថកិច្ចរបស់គាត់ប៉ុណ្ណោះ។ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១២៣ បានចែងថា ចៅក្រមដែលមានសមត្ថកិច្ចគឺ

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នាហើយ ទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ការសម្រេចនេះបទផ្លូវតវ៉ា។

#### ១.១.២.សមត្ថកិច្ចតាមសាច់រឿង

តាមក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានទទួលស្គាល់ថាតុលាការទាំងឡាយអាចប្តឹងមកខ្លួនឯងដោយខ្លួនឯងផ្ទាល់ដើម្បីបើកការស៊ើបសួរ ឬវិនិច្ឆ័យលើបទល្មើសព្រហ្មទណ្ឌណាមួយឡើយ ទោះជាតុលាការនោះបានដឹងក៏ដោយ។ ដូច្នេះចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរអាចស៊ើបសួរបានលុះត្រាតែបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲស៊ើបសួរពីព្រះរាជអាជ្ញា ឬដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ចៅក្រមស៊ើបសួរមានសមត្ថកិច្ចចំពោះប្រភេទបទល្មើសទាំងបីផងដែរ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ គ្រប់បទឧក្រិដ្ឋទាំងអស់ត្រូវតែបើកការស៊ើបសួរជានិច្ច ចំពោះបទមជ្ឈិមវិញបើកការស៊ើបសួរក៏បាន មិនបើកការស៊ើបសួរក៏បាន។

## ១.២. សភាស៊ើបសួរ

សភាស៊ើបសួរ គឺជាយុត្តិធិការនៃនីតិរូមថ្នាក់ទី ២ ដែលមានទីតាំងស្ថិតនៅក្នុងសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ច លើបណ្តឹងតវ៉ាដែលសម្រេចសេចក្តីដោយចៅក្រមស៊ើបសួរ។ សមាជិកនៃសភាស៊ើបសួរ មិនអាចត្រូវជ្រើសរើសចេញពីចៅក្រមស៊ើបសួរ លើសំណុំរឿងក្តីដែលខ្លួនកំពុងមានសមត្ថកិច្ចនោះឡើយ។

តួនាទីចំបងរបស់សភាស៊ើបសួរ គឺតួនាទីដែលទាក់ទងការងារនឹងយុត្តាធិការស៊ើបសួររបស់ខ្លួនផ្ទាល់។ រាល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ បើកផ្លូវប្តឹងតវ៉ាដោយអង្គព្រះរាជអាជ្ញានិង ព្រះរាជអាជ្ញា។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។ ក្រៅពីអគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់ដើមនៃវត្ថុដែលត្រូវបានរឹបអូស ក៏អាចប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរបានផងដែរ។

## ១.៣.ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ

ក្នុងនាមជាចៅក្រមស៊ើបសួរមួយរូប ទោះជាបានដឹងពីរឿងបទល្មើសណាមួយក៏ដោយ គឺមិនអាចបើកស៊ើបសួរបាននោះទេ លុះត្រាតែបានទទួលពាក្យបណ្តឹងតាមរយៈព្រះរាជអាជ្ញា។

### ១.៣.១.ប្រភេទនៃបណ្តឹង

ការស៊ើបសួរត្រូវបានបើកដោយ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរនេះអាចធ្វើឡើងប្រឆាំងនឹងជនស្គាល់ឈ្មោះ ឬជនមិនស្គាល់ឈ្មោះ។ ក្នុងករណីដែលពុំមានចង្អុលប្រាប់ឈ្មោះយើងអាចនិយាយថាការស៊ើបសួរត្រូវបើកប្រឆាំងនឹងអញ្ញាតជន ជនមិនស្គាល់ឈ្មោះ។ ហើយក៏ជាវិធានការដែលត្រូវគោរពផងដែរ បើពុំនោះទេនឹងមានមោឃភាពនៃនីតិវិធី។ ដូច្នេះដីកាសន្និដ្ឋាននេះ គឺជាលិខិតដែលបើកឲ្យមានបណ្តឹងអាជ្ញាដែលព្រះរាជអាជ្ញា ប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឲ្យធ្វើការស៊ើបសួរលើអង្គហេតុមួយ ឬច្រើនជាកំណត់ដែលអាចត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាសអំពីអង្គហេតុដែលបញ្ជូនទៅចៅក្រមស៊ើបសួរ។ ក្នុងការអនុវត្តជាក់ស្តែងសេចក្តីសន្និដ្ឋានត្រូវមានភ្ជាប់មកជាមួយនឹងលិខិតផ្សេងៗដែលកំណត់ពីអង្គហេតុ ។

ក្នុងករណីនេះគ្រាន់តែអ្នកចុះហត្ថលេខាផ្តល់នូវទិដ្ឋាការលើលិខិតទាំងនោះ វាគ្រប់គ្រាន់ទៅហើយព្រោះវាមានតម្លៃស្មើនឹងការវិភាគលិខិតនេះ។ លិខិតភ្ជាប់ត្រូវបានសន្មត់ថា មានផ្ទុកនូវគ្រប់ការចង្អុលបង្ហាញដែលចាំបាច់នានាសម្រាប់បំភ្លឺដល់ចៅក្រមស៊ើបសួរ និងដើម្បីអនុញ្ញាតឲ្យគាត់កំណត់ពីកម្មវត្ថុពិតប្រាកដក្នុងលិខិតភ្ជាប់នោះ។ ព្រមទាំងវិសាលភាពនៃបណ្តឹងដោយផ្អែកទៅលើការចង្អុលបង្ហាញជាទូទៅលិខិតភ្ជាប់គឺជាលិខិតដែលចេញក្នុងពេលស៊ើបអង្កេតជាក់ស្តែង ឬពេលស៊ើបអង្កេតបឋម។ ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ

ជានិច្ចកាល គឺជាលិខិតលាយល័ក្ខណ៍អក្សរដែលត្រូវតែមានចុះកាលបរិច្ឆេទ និងហត្ថលេខា បើពុំនោះទេនឹងនាំឲ្យមានមោឃភាពទាំងដីកា និងលិខិតផ្សេងៗទៀតដែលចេញក្រោយមកទៀត ។

- **បណ្តឹងជនរងគ្រោះដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ចៅក្រមស៊ើបសួរក៏អាចទទួលបណ្តឹងតាមរយៈបណ្តឹងជនរងគ្រោះដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយជនរងគ្រោះខ្លួនឯងផ្ទាល់ ឬដោយមេធាវី ក្នុងនាមរបស់ជនរងគ្រោះ បន្ទាប់ពីធ្វើការកត់សំគាល់តាមដីកានូវការដាក់ពាក្យបណ្តឹងរួចមក ចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋាន។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចធ្វើឡើងប្រឆាំងជនស្គាល់ឈ្មោះ ឬជនមិនស្គាល់ឈ្មោះ។ គួរកត់សំគាល់ថាក្នុងគ្រប់ករណីទាំងអស់ត្រូវមានលិខិតរបស់អយ្យការ។ ដូច្នេះបណ្តឹងអាជ្ញានឹងត្រូវបានបើកដោយត្រឹមត្រូវដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបស់ព្រះរាជអាជ្ញាបដិសេធក៏ដោយ។ ទោះបីជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវប៉ុន្តែព្រះរាជអាជ្ញាអាចសុំកុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយសារមានការរលត់បណ្តឹងអាជ្ញា ឬដោយសារអវត្តមាននៃបទល្មើសព្រហ្មទណ្ឌព្រោះអំពើដែលបរិហារដោយជនរងគ្រោះមិនអាចត្រូវបានស្តីបន្ទោសបាន។

នោះតុលានឹងបើកការសាកសួរពីជននោះដើម្បីធ្វើការពិចារណាក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬលើកលែងបទចោទ ។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនបន្តការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុដែលត្រូវជូនដំណឹងដល់ជនរងគ្រោះ។ ភាគីរដ្ឋប្បវេណី និងព្រះរាជអាជ្ញាអាចធ្វើ បណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលអាចជាដីកាមិនព្រមស៊ើបសួរ ឬដីកាប្រកាសរឿងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរធ្វើសេចក្តីសន្និដ្ឋានមិនស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធដោយសំអាងហេតុដែលត្រូវ ជូនដំណឹងទៅដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងខ្លីបំផុត។

ដើម្បីការពារកុំឲ្យមានពាក្យបណ្តឹងដោយបំពានចៅក្រមស៊ើបសួរកំណត់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុក ដែលផ្អែកលើធនធាន និងបន្ទុករបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏កំណត់ពីរយៈដែលត្រូវបង់ប្រាក់តម្កល់ទុកនោះផងដែរ។

### ១.៣.២.វិសាលភាពនៃបណ្តឹង

វិសាលភាពចំពោះអង្គហេតុជាគោលការណ៍ចៅក្រមស៊ើបសួរ ស៊ើបតែអំពីអង្គហេតុដែលព្រះរាជអាជ្ញាប្តឹងមកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប៉ុណ្ណោះ។ ប្រសិនបើការស៊ើបសួរលេចអង្គហេតុថ្មី ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះកាន់ទៅព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរចំពោះអង្គហេតុថ្មីនេះដោយដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ប៉ុន្តែប្រសិនបើអង្គហេតុថ្មីនោះជា

ស្ថានទម្ងន់នៃបទល្មើស ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរដោយមិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ។

វិសាលភាពចំពោះបុគ្គលជាគោលការណ៍ចៅក្រមស៊ើបតែធ្វើឡើងចំពោះអង្គហេតុ និងបុគ្គលដែលព្រះរាជអាជ្ញាប្តឹង មកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ជននោះជាកម្មវត្ថុនៃការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ។ ប្រសិនបើការស៊ើបសួរមានតម្រុយច្បាស់ និងស៊ីសង្វាក់គ្នាថាបុគ្គលផ្សេងជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើស ចៅក្រមស៊ើបសួរ អាចដាក់ជននោះឲ្យស្ថិតនៅក្រោមការពិនិត្យដោយការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមមាត្រា ១៤៣ ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិតប្រសិនបើជននោះមានវត្តមាននៅកាលបរិច្ឆេទបង្ហាញខ្លួនលើកដំបូង។ ប៉ុន្តែការអនុវត្តខ្លះ ចៅក្រមស៊ើបសួរចេញដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ(ស្មើនឹងចោទប្រកាន់) ហើយជូនដំណឹងទៅសាមីខ្លួន។

### ១.៤.ការបញ្ចប់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

ការបញ្ចប់ការស៊ើបសួរត្រូវបានបញ្ចប់តាមរយៈ ការជូនដំណឹងអំពីកិច្ចបញ្ចប់ការស៊ើបសួរ ការបញ្ចប់ការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី ដីកាដំណោះស្រាយ និងអនុភាពនៃដីកាដំណោះស្រាយ ។

#### ១.៤.១.ការជូនដំណឹងអំពីកិច្ចបញ្ចប់ការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។ ២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាត្រួតពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា)។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និងក្នុងរយៈ ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង ។ ចិរវេលានេះត្រូវគិតពី ថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ការស៊ើបសួរត្រូវបានបញ្ចប់នោះព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់ ។

#### ១.៤.២.ការបញ្ចប់ការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី

ការសម្រេចបិទការស៊ើបសួរជានិច្ចកាលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែចិរវេលានៃការបិទការស៊ើបសួរនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំមានចែងកំណត់ពេលណាមួយច្បាស់លាស់នោះទេ។ យុត្តិធម៌ដែលប្រកបដោយភាពយឺតយ៉ាវស្មើនឹងអយុត្តិធម៌។ នេះគឺជាពាក្យស្លោកមួយដែលត្រូវបានអ្នកតាក់តែងច្បាប់ និងអ្នក

អនុវត្តច្បាប់យកមកពិចារណាទៅតាមស្ថានភាពសង្គមជាក់ស្តែង។ កាលបើរឿងក្តីមួយត្រូវបានអូសបន្លាយរយៈពេលយូរហួសហេតុវាជាផលវិបាកដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិភាគីផងដែរ។ ហេតុផលនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវបទប្បញ្ញត្តិមួយចំនួនដែលអនុញ្ញាតឲ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុងដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចៀសភាពអសកម្មនៃកិច្ចនីតិវិធីស៊ើបសួរ។ ភាគីនៃរឿងក្តីព្រហ្មទណ្ឌ ជាអាទិ៍ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិធ្វើពាក្យស្នើសុំឲ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរបាន។

- នៅពេលផុតចិរវេលា ១ ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឲ្យបិទការស៊ើបសួរ ។
- នៅពេលផុតចិរវេលា ១ ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យបិទការស៊ើបសួរ។

ក្នុងរយៈពេល ១ ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ស៊ើបសួរត្រូវតែសម្រេច ។ ប្រសិនបើ ចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេដែលធ្វើអធិបញ្ញាឲ្យចៅក្រមស៊ើបសួរសម្រេច។អ្នកស្នើសុំអាចប្តឹងទៅប្រធានសភាស៊ើបសួរពាក្យសុំឲ្យបិទការស៊ើបសួរអាចត្រូវប្រើប្រាស់ដោយមេធាវីបាន ។

### ១.៤.៣.ដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ជាដីកាលើកលែងចោទប្រកាន់។ ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬជាបទលហុ ចៅក្រមស៊ើបសួរត្រូវសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់និងឈ្មោះបទល្មើស។ ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណី ៖

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ។
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះ ចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ដីការដំណោះស្រាយត្រូវសម្រេចផងដែល អំពីការឃុំខ្លួនបណ្តោះអាសន្ន ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការប្រគល់វត្ថុចាប់យក។

### ១.៤.៤.អានុភាពនៃដីកាដំណោះស្រាយ

កាលណាដីកាដំណោះស្រាយចូលជាស្ថាពរនាំមកនូវៈ

- លុបលាងមោឃភាពនីតិវិធីមុនៗធ្វើអោយបុគ្គលទាំងឡាយមិនអាចលើកយកនូវមោឃភាពនៃកិច្ចស៊ើបអង្កេត ឬស៊ើបសួរនៅចំពោះមុខយុត្តាធិការជំនុំជម្រះបានទៀតឡើយ។
- ព្រមទាំងនាំមកឲ្យមានការរំលត់បណ្តឹងអាជ្ញាចំពោះជនត្រូវចោទកាលណាចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទ។ ប៉ុន្តែករណីនេះព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរអាចបើកការស៊ើបអង្កេត ឬស៊ើបសួរម្តងទៀតឡើងវិញ កាលណាលេចឡើងនូវបន្ទុកថ្មីនៅថ្ងៃក្រោយ។

## ផ្នែកទី២ សិទ្ធិអំណាចចៅក្រមស៊ើបសួរ

### ២.១.អំណាចបង្ខំរបស់ចៅក្រម

ដើម្បីធានានូវប្រសិទ្ធិភាពនៃនីតិវិធីស៊ើបសួរប្រព្រឹត្តទៅបានរលូនជោគជ័យច្បាប់បានប្រគល់សិទ្ធិអំណាចឲ្យចៅក្រមស៊ើបសួរប្រើប្រាស់វិធានការនិរន្តរាយ ដូចជាការចេញដីកា ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ និងការរក្សាជនត្រូវចោទឲ្យស្ថិតក្រោមការចាត់ចែងរបស់តុលាការ ។

#### ២.១.១. ការចេញដីកា

ចៅក្រមស៊ើបសួរ មានអំណាចក្នុងការបញ្ជាឲ្យស្វែងរក និងបញ្ជាឲ្យចូលខ្លួនចំពោះបុគ្គលដែលមិនព្រមឆ្លើយតបតាមការកោះហៅ។

អនុលោមតាមមាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីដីកាមាន ៤ ប្រភេទដូចជា ដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន ។

➢ **ដីកាបង្គាប់ឲ្យចូលខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួនបាន ។ ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ដីកាបង្គាប់ឱ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចូលខ្លួននិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។ តាមរយៈដីកានេះ សាមីខ្លួនបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដោយសេរី មានន័យថា ការបង្ហាញខ្លួនតាមរយៈដីកានេះ ពុំមានតម្លៃបង្ខំដោយកងកម្លាំងសាធារណៈនោះទេ។ ដីកានេះ គឺជាបញ្ជាឲ្យសាមីខ្លួនចូលបង្ហាញខ្លួនតាមផ្លូវធម្មតា ដែលជាទូទៅ ដីកានេះត្រូវបានប្រើប្រាស់នៅពេល ដែលសាមីជននោះមិនបានរត់គេចខ្លួន ហើយពុំឆ្លើយតបទៅនឹងការកោះហៅតាមផ្លូវរដ្ឋបាល ។

- **ដីកាបង្គាប់ឲ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យនាំខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។ ដីកាបង្គាប់ឱ្យនាំខ្លួន មាននិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើម្បីឲ្យដីកានេះត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងអនុវត្តបេសកកម្មរបស់ខ្លួនផងដែរ ។ ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

### ➢ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។ ចៅក្រមស៊ើបសួរនឹងអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ ៖

១-បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

២-បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ មុនចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពេលទទួលយោបល់ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាជាអ្នកទទួលរ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ ដីកាបង្គាប់ឱ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមាន ចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួនផងដែរ។

ការបង្ហាញខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួន ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុ នៃដីកាបង្គាប់ឱ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវ

ចាត់ចែងដោយអយ្យការ។ ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ។ ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

- **ដីកាបង្គាប់ឲ្យឃុំខ្លួន**

ដីកានេះ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន លុះត្រាតែមានសេចក្តីសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន ហើយអាចបង្គាប់ឲ្យឃុំខ្លួនបុគ្គលណាម្នាក់បានលុះត្រាតែជនត្រូវចោទនោះជា កម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ត្រង់ចំណុចចុងក្រោយនេះ បញ្ជាក់យ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលតាមន័យនេះ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបុគ្គលណាម្នាក់ ដោយមិនមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះឡើយ ។

- **ការអនុវត្តដីកា**

ដីកាត្រូវបានអនុវត្តនៅលើវិសាលភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ដីកានេះអនុវត្តរហូតដល់មានលិខិតជាក់លាក់ពីតុលាការ ដែលដកយកមកវិញ ជំនួសមកវិញ ឬលុបចោលនូវដីកាទាំងនោះ ។ ដូចនេះវិនិច្ឆ័យដែលសម្រេចពីជោគវាសនារបស់បុគ្គលដែលពាក់ព័ន្ធក្នុងការសម្រេចទុកដីកាទាំងនេះជាមោឃៈ ឬចេញដីកាផ្សេងទៀត ។

គ្រប់ដីកាទាំងអស់មានលក្ខណៈរួមមួយគឺបង្ខំឲ្យមានការសួរចម្លើយបុគ្គលដែលពាក់ព័ន្ធដោយ ចៅក្រមស៊ើបសួរ ដែលចេញដីកាក្នុងពេលណាមួយនៃនីតិវិធីក៏បាន ។ ជាអាទិ៍នៅក្នុងដីកាបង្គាប់ឲ្យចូលខ្លួន ចៅក្រមត្រូវសួរចម្លើយភ្លាមចាប់តាំងពីពេលបុគ្គលនោះបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ។

ចំពោះដីកាបង្គាប់ឲ្យនាំខ្លួនវាធ្វើឡើងក្នុងលក្ខខណ្ឌតែមួយនឹងដីកាបង្គាប់ឲ្យចូលខ្លួន មានន័យថា ការសួរចម្លើយដោយចៅក្រមស៊ើបសួរ ត្រូវធ្វើភ្លាម លើកលែងតែមានឧបសគ្គ ។

ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន ចាប់ផ្តើមពីការជូនដំណឹងទៅបុគ្គលដែលចៅក្រមស៊ើបសួរចង់ស្តាប់ចម្លើយនៅក្នុងការិយាល័យ ឬមន្ទីរស៊ើបសួររបស់ចៅក្រមស៊ើបសួរ នៅថ្ងៃ និងម៉ោងដែលបានកំណត់ក្នុងដីកានោះ។ អត្ថប្រយោជន៍របស់ដីកានេះ មានតិចតួច បើប្រៀបធៀបទៅនឹងការកោះហៅ ធម្មតារបស់រដ្ឋបាល ។ ចាប់ពីពេលនេះ បុគ្គលពាក់ព័ន្ធដឹងថាខ្លួនឯងត្រូវបានសង្ស័យ ហើយបើសិនជា មិនចូលបង្ហាញខ្លួននៅការិយាល័យរបស់ចៅក្រមស៊ើបសួរទេ ដំណាក់បន្ទាប់ច្បាស់ជាដីកាបង្គាប់ឲ្យនាំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួន ។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវឲ្យដំណឹងដល់បុគ្គលដែលជាកម្មវត្ថុនៃដីកាដោយអាជ្ញាសាលា ដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ដែលត្រូវបានប្រគល់លិខិតចំលងឲ្យបុគ្គលពាក់ព័ន្ធ បន្ទាប់ពីបុគ្គលនេះបានចុះហត្ថលេខាលើសំណៅដើម ដែលត្រូវប្រគល់ឲ្យទៅចៅក្រមស៊ើបសួរវិញ ។

ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវប្រគល់ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ដីកាទាំងនេះត្រូវផ្សព្វផ្សាយតាមគ្រប់មធ្យោបាយក្នុងករណីបន្ទាន់ ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងផ្ទះដែលជនពាក់ព័ន្ធស្នាក់នៅមុនម៉ោង ០៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចឡើយ ។

### ២.១.២. ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

តាមបញ្ញាប្បត្តិមាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាៈ

ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឲ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឲ្យស្ថិតក្រោមការពិនិត្យក្នុងឋានៈជា ចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

#### ២.១.២.១.បុគ្គលដែលអាចដាក់ឲ្យស្ថិតក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរ វាយតម្លៃអំពីកាលានុវត្តភាពនៃការជូនដំណឹងពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យជាយថាហេតុបន្ទាប់ពីបានធ្វើការស៊ើបសួរចាំបាច់ផ្សេងៗ រួចមក ។

ចៅក្រមស៊ើបសួរត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញាត្តិនូវការគ្មានលទ្ធភាពក្នុងការសួរយកចម្លើយលើបុគ្គលដែលមានតម្រុយពិរុទ្ធក្នុងឋានៈជាសាក្សី ដោយអនុលោមតាមមាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ការបញ្ញាត្តិបែបនេះ គឺជារក្សានូវការគោរពសិទ្ធិមនុស្ស ដែលអាចត្រូវបំពាន់យ៉ាងធ្ងន់ធ្ងរដោយកិច្ចស៊ើបសួរ ដែលជាគោលការជនត្រូវចោទមានសិទ្ធិក្នុងការពឹងពាក់មេធាវីការពារសិទ្ធិរបស់ខ្លួន ។

ក្រោយពីនេះ បុគ្គលដែលត្រូវបានកំណត់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបានតែក្នុងឋានៈជាជនត្រូវចោទតែប៉ុណ្ណោះ ។

#### ២.១.២.២.បែបបទនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

ការដាក់ឲ្យស្ថិតក្រោមការពិនិត្យធ្វើឡើងនៅពេលដែលជនពាក់ព័ន្ធចូលបង្ហាញខ្លួនដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ។ បែបបទនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យមានក្នុងមាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាៈ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់

ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម ។

ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី ។

ក្រោយពីការចូលបង្ហាញខ្លួនលើកទី១ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន
- គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

ការឲ្យដំណឹងព្រមទាំងការប្រកាសស្តីពីការផ្លាស់ប្តូរអាស័យដ្ឋាន ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

ជនត្រូវចោទអាចត្រូវបានបកដោយអ្នកបកប្រែ ដែលអ្នកបកប្រែត្រូវស្បថតាមជំនឿសាសនារបស់ខ្លួនថានឹងជួយដល់តុលាការ និងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយរបស់ជនត្រូវចោទ ។

- **អានុភាពនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យ**

បុគ្គលដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យរបស់តុលាការនោះបុគ្គលនឹងទទួលបានឋានៈជាជនត្រូវចោទ ដែលក្លាយខ្លួនទៅជាភាគីនៃសំណុំរឿងក្តីព្រហ្មទណ្ឌ ។ សិទ្ធិរបស់ជនត្រូវចោទ មានសិទ្ធិការពារខ្លួនដែលស្តែងឡើងតាមសិទ្ធិទទួលបាននូវជំនួយមេធាវីតាមលក្ខន្តិកៈមេធាវី សិទ្ធិចូលរួមក្នុងការពារខ្លួន ដោយឆ្លើយ ឬមិនឆ្លើយ សិទ្ធិត្រូវបានស្តាប់ដោយចៅក្រម និងមិនមែនដោយមន្ត្រីនគរបាលយុត្តិធម៌ សិទ្ធិទទួលព័ត៌មានពីសកម្មភាពខាងផ្នែកតុលាការរបស់ចៅក្រមស៊ើបសួរ សិទ្ធិសុំមោឃនីតិវិធី សិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើរការស៊ើបសួរដែលសុំទៅឲ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវមួយចំនួន ។ ជាអាទិ៍ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយភាគីរដ្ឋប្បវេណី ឬសាក្សី ធ្វើការសួរចម្លើយតទល់ ឬចុះទៅទីកន្លែងណាមួយ ។ ការស្នើសុំនេះត្រូវធ្វើឡើជាលាយល័ក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុដែលអនុញ្ញាតឲ្យបញ្ជាក់ពីប្រយោជន៍របស់វា។

### ២.១.៣.ការរក្សាជនត្រូវចោទឲ្យស្ថិតក្រោមការចាត់ចែងរបស់តុលាការ

ដើម្បីធានាឲ្យបាននូវការរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តនូវវិធានការសំខាន់បី ដែលផ្តល់ឲ្យចៅក្រមស៊ើបសួរនូវអំណាចបង្ខំច្រើន ឬតិច គឺការឃុំខ្លួនបណ្តោះអាសន្ន ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

- **ការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព លើកលែងតែក្នុងករណីពិសេស ជនត្រូវចោទ អាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកទី ៥ ជំពូកទី៣ មាតិកាទី១ គន្ថីទី ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាប់ពីមាត្រា ២០៣ ដល់មាត្រា ២១៨ ។

ដើម្បីអនុវត្តនូវវិធាននៃការឃុំខ្លួនបណ្តោះអាសន្នបាន ត្រូវតែគោរពនូវលក្ខខណ្ឌដាច់ខាតមួយចំនួន ។ ជានិច្ចកាល ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបាន លុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទឧក្រិដ្ឋ ។ ចំពោះបទមជ្ឈិមវិញ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបានលុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទមជ្ឈិមដែលច្បាប់កំណត់ចិរវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ ឆ្នាំ ។ រយៈពេលស្មើ ឬលើសពី ១ ឆ្នាំនេះ សំដៅដល់អតិបរិមានៃទោសនីមួយៗ ដែលមានបញ្ញតិក្នុងច្បាប់ ។

យោងតាមការវិភាគលើផ្នែកទី ៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ននេះឃើញថា៖ ការអនុវត្តវិធាននៃការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចអនុវត្តបានឡើយ ចំពោះករណីដូចខាងក្រោម៖

- បទល្មើសលហុ
- បទល្មើសមជ្ឈិម ដែលមានទណ្ឌកម្មពិន័យជាប្រាក់ ឬមានទណ្ឌកម្មដាក់ពន្ធនាគារតិចជាង ១ ឆ្នាំ ។
- បុគ្គលដែលរងការចោទប្រកាន់ជាអនីតិជន អាយុតិចជាង ១ ឆ្នាំ ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរងចាំសេចក្តីសម្រេចរបស់តុលាការ ។

ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានសំអាងហេតុ យោងតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីអំពីមូលហេតុនៃការឃុំខ្លួននេះ ដែលជាករណីពិសេស និងជាភាពចាំបាច់ដើម្បី៖

- បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ។
- រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនរងគ្រោះ ជនត្រូវចោទ និងអ្នកសមគំនិត ។
- រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

- ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។
- ការពារសន្តិសុខឲ្យជនត្រូវចោទ ។
- ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។

ការសម្រេចថានឹងត្រូវឃុំខ្លួនជនត្រូវចោទ អាចផ្តើមដោយគំនិតផ្ទាល់ខ្លួនរបស់ចៅក្រមស៊ើបសួរ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា (យោងតាមក្រមនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងសុំវិធាននេះដោយផ្ទាល់ទៅចៅក្រមស៊ើបសួរទេ ប៉ុន្តែអាចធ្វើឡើងតាមរយៈព្រះរាជអាជ្ញា) ហើយត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ និងឲ្យមេធាវីបង្ហាញមធ្យោបាយការពារខ្លួនបើសិនជាមាន ។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានសំអាងហេតុ ដោយយោងតាមបញ្ញត្តិមាត្រា ២០៥ ស្តីពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ។ យោងតាមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដែលជាបញ្ជាដល់ប្រធានពន្ធនាគារឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ ។ ដីកាបង្គាប់ឲ្យឃុំខ្លួន បណ្តោះអាសន្ននេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

➢ **ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

យោងតាមមាត្រា ២០៨, ២០៩, ២១០, ២១៣ និង២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានបែងចែកតាមចំណាត់ថ្នាក់នៃបទល្មើស ជាបីសណ្ឋានគឺ ៖

១-បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

២-បទឧក្រិដ្ឋនៃនីតិសមាញ្ញ

៣-បទមជ្ឈិម (ទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ) ។

➢ **ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ មិនអាចលើសពី ១ ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ ប៉ុន្តែអាចពន្យារពេលបានពីរដង ដោយក្នុងមួយដងៗ មានថិរវេលា ១ ឆ្នាំ។

➢ **ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋ ត្រូវបានបែងចែកជា៣ផ្នែក តាមនីតិភាពនៃបុគ្គលដែលរងការចោទប្រកាន់ ដូចខាងក្រោម៖

១-នីតិជន ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែ បានទេ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលបានពីរដង ដោយក្នុងមួយដងៗ មានថិរវេលា ៦ ខែ ។

២-អនីតិជន អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែបានទេ កាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានឡើយ ។

៣-អនីតិជន អាយុចាប់ពី ១៨ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែ បានទេ កាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ ។

➢ **ការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម**

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីបទមជ្ឈិម ក៏ត្រូវបានបែងចែកជា៣ផ្នែក តាមនីតិភាពនៃបុគ្គលដែលរងការចោទប្រកាន់ ដូចខាងក្រោម៖

១-នីតិជន ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែ បានទេ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលបានម្ដងគត់ ដោយមានថិរវេលាមិនឲ្យលើសពី ២ ខែ បានឡើយ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់នោះឡើយ ។

២-អនីតិជន អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែ បានទេ កាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ ។

៣-អនីតិជន អាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ ខែ បានទេ កាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី២ និងទី៣ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាល នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

➢ **ដីកាឃុំខ្លួនបណ្ដោះអាសន្ន**

ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រា។ ចំពោះការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យ ឃុំខ្លួនរហូតទាល់តែបានទទួលការ ឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

➢ **ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ**

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទ ឲ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។ ហើយការដោះលែងក៏អាចធ្វើឡើង តាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ឬបណ្ដឹងសុំរបស់ជនត្រូវចោទផងដែរ ។

➢ **ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ**

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងឲ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរត្រូវជូន ព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ដោយបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ហើយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី ៥ ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿងមកពិនិត្យ) ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ប៉ុន្តែមានករណីពិសេស ដែលមានភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញានោះឡើយ តែចៅក្រមស៊ើបសួរត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃភាពបន្ទាន់នោះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

➢ **ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំតាមការប្ដឹងសុំរបស់ព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឲ្យដោះលែងជនត្រូវចោទបាន ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ។ បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

➢ **ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំដោយជនត្រូវចោទ**

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទ និងសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាម ដើម្បីពិនិត្យ និងផ្ដល់យោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី ៥ ថ្ងៃ គិតពី ថ្ងៃទទួលសំណុំរឿងមកពិនិត្យនោះឡើយ) ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទអាចធ្វើពាក្យប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

ក្នុងករណីដែលមានការបដិសេធនឹងពាក្យសុំឲ្យនៅក្រៅឃុំ ជនត្រូវចោទអាចដាក់ពាក្យសុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវតែសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

នៅក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ដីកាសម្រេចនេះ ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងប្រធានពន្ធនាគារ ។ បទប្បញ្ញត្តិនៃមាត្រា ២៧៦ ស្តីពីការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ។

មាត្រា ២៧៦ ស្តីពីការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាពនៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាៈ កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទ ដែលកំពុងជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី ។

ត្រូវធ្វើដូចគ្នានេះដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកានេះមានអានុភាពនាំឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ ។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីការបដិសេធដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍ ។

កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- **ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

តាមក្រមនីតិវិធីព្រហ្មទណ្ឌពុំបានឲ្យនិយមន័យនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ប៉ុន្តែយើងអាចកំណត់បានថា វាជាវិធានការនិរន្តរាយមួយ ដូចករណីនៃការឃុំខ្លួនបណ្តោះអាសន្នដែរ គ្រាន់តែវាជាវិធានមួយដែលមានស្ថានភាពស្រាលជាង ។ ចៅក្រមស៊ើបសួរបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពនូវកាតព្វកិច្ចមួយឬច្រើន ដូចបានកំណត់ក្នុងបទប្បញ្ញត្តិមាត្រា ២២៣ នៃក្រមនេះ ។

យោងតាមការពិនិត្យលើខ្លឹមសារនៃមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏អាចឲ្យកំណត់បានថាការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានមួយដែលមានកម្មវត្ថុដាក់ ជនត្រូវចោទឲ្យស្ថិតក្រោមការរឹតបន្តឹងខាងសេរីភាពមួយចំនួនតាមរយៈកាតព្វកិច្ច ឬការហាមឃាត់ដែល កំណត់ដោយច្បាប់ដែលវិធាននេះត្រូវបានចងក្រងក្រោមគោលដៅ ៤ ផ្សេងៗគ្នា៖

- ធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទ
- គោរពនូវវិធានផ្សេងៗដែលសំដៅលប់បំបាត់ពីជីវិតរបស់ជនត្រូវចោទនូវធាតុមួយចំនួន
- ដាក់កំហិតនូវការព្យាបាលខាងផ្នែកសង្គម និងផ្នែកវេជ្ជសាស្ត្រ
- ចេញនូវបញ្ញត្តិផ្សេងៗ ដើម្បីធានាឲ្យបាននូវសិទ្ធិរបស់ជនរងគ្រោះ

អាចមានការភាន់ច្រឡំខ្លះទាក់ទងទៅនឹងវិធានខាងលើនេះជាពិសេសត្រង់ចំណុចទី ៩ នៃមាត្រា ២២៣ ដែលបញ្ញត្តិអំពីកាតព្វកិច្ចមួយ ដែលតម្រូវឲ្យជនត្រូវចោទដាក់ប្រាក់ធានា ។ ត្រង់ចំណុចនេះ មានមតិខ្លះថាការបង្គាប់ឲ្យជនត្រូវចោទដាក់ប្រាក់ធានា គួរទាមទារឲ្យមានស្ថាប័នជំនាញធ្វើការវាយតម្លៃទៅលើកាលទេសៈមួយចំនួនដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលបានកើតឡើង ដើម្បីកំណត់អំពីចំនួនទឹកប្រាក់ដែលត្រូវដាក់ធានានោះ។ **ឧទាហរណ៍** ពាក់ព័ន្ធនឹងបទបង្ករបួសដោយចេតនា គឺតម្រូវឲ្យគ្រូពេទ្យវាយតម្លៃអំពីស្ថានភាពរបួសជាមុនសិន ដើម្បីឲ្យដឹងពីទំហំព្យសនកម្ម (ទំហំនៃសំណងការព្យាបាលរបួស) ក្នុងគោលបំណងឲ្យជនត្រូវចោទដាក់ប្រាក់ធានាឲ្យធនល្មមនឹងសំណងផ្នែករដ្ឋប្បវេណីនៃព្យសនកម្មដែលកើតឡើងនោះ ។

យោងតាមមាត្រា ៤៤ មាត្រា ៤៥ និងមាត្រា ១២២ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។ រីឯបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ។ តាមខ្លឹមសារនៃមាត្រាទាំងបីនេះបញ្ជាក់ឲ្យឃើញថាបទលហុពុំត្រូវបានអនុញ្ញាតឲ្យបើកការស៊ើបសួរនោះទេ។ ផ្ទុយទៅវិញ មាត្រា ៤៩ បានកំណត់ថាប្រសិនបើរឿងនោះ ជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងក្នុងមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហេតុដូចនេះ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចអនុវត្តបានចំពោះបទលហុនោះទេដោយហេតុថាវិធានការនេះត្រូវបាន អនុវត្តតែក្នុងយុត្តាធិការស៊ើបសួរតែប៉ុណ្ណោះ ឯបទលហុត្រូវបានអនុវត្តតាមនីតិវិធីកោះហៅបញ្ជូនទៅយុត្តាធិការជំនុំជម្រះដោយផ្ទាល់ដោយមិនឆ្លងកាត់យុត្តាធិការស៊ើបសួរនោះឡើយ ។

ចៅក្រមស៊ើបសួរអាចអនុវត្តនូវវិធាននេះបានតាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរ បដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញាអំពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលយ៉ាងខ្លីបំផុត ។

បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេចព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

- **ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបាន គ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ ។ សេចក្ដីសម្រេចនេះត្រូវជូន ដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

- **ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឲ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ។ បើសិនជារយៈពេល ៥ ថ្ងៃនេះ កន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹង ក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

- **ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ**

